សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
# KhmerPost USA
Advertising: **PA/NJ/NY: (267) 253-3947 MA/RI: (978) 656-8141**

**Vol 07 Issue 125 March8th- 21st. 2013**



| មាតិការឿង | ទំព័រ |
|---|---|
| ១-ស្ថាបីស្ថាបត្យកម្មដែកបុរាណនៅស្រុក | ០៣ |
| ២-ខ្មែរអ្នកជាតិនិយម | ០៤ |
| ៣-អ្នកមានចិត្តអ្នកក្រនៅប្រទេសខ្មែរ | ០៥ |
| ៤-The Cambodia daily | ០៦និង០៩ |
| ៥- ក្បួនវិភាគសរាយការណ៍ពី | ០៧ |
| ៦-សុខភាព និងម្ហូបអាហារយើងបរិភោគ | ០៨ |



32 Wamesit St., Lowell, MA 01852. **Phone-Fax (978) 656 8141** www.khmerpost.us


# វិចារណកថា
## រជ្ជកាលបន្ទាប់ពីសីហនុ



**តពីលេខមុន**
**"ភ្នំភ្លើងត្រៀមផ្ទុះនៅកម្ពុជា"**
**ដោយ : ពិន សំខុន**
**ហេតុអ្វីក៏"ភ្នំភ្លើងដេក"នេះ ពុំព្រមភ្ញាក់?**

ចាប់តាំងពីក្រោយសម័យអង្គរមកសង្គមខ្មែរបានបាក់បែកខ្ចាត់ខ្ចាយថមថយកម្លាំងសាមគ្គីថមថយទស្សនៈស្នេហាជាតិ ខ្វះការរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ ប្រទេសជាតិរកកល្យ នឹងរលាយដូចប្រទេសចាមច្រើនដង ការទៅពឹងពាក់បរទេសដែលមានកម្លាំងច្រើនឱ្យមកការពារផលប្រយោជន៍ខ្លួន គឺជារឿងធម្មតានៃជនជាតិអន់ខ្សោយ ។ ដែនដីនៃចក្រភពកម្ពុជាដ៏ធំធេងនៃសតវត្សទី១១បានក្លាយមកនៅតូច ហើយការពារស្ទើរមិនបាននាសតវត្សទី២០ ។ សម្ដេចនរោត្ដម សីហនុ ក្នុងរជ្ជកាលប្រមាណ៥០ឆ្នាំរបស់ព្រះអង្គ ថ្វីត្បិតតែទ្រង់មិនសូវជឿជាក់ទៅលើលទ្ធិប្រជាធិបតេយ្យដែលបារាំងបានបន្សល់ទុកឱ្យកម្ពុជាតែព្រះអង្គបានទ្រទ្រង់ **តទៅទំព័រទី ០៧**

# ចន កែរី ថា ប្រកឱកាស
## សម្រាប់អ៊ីរ៉ង់មិនបើកចំហរហួតនោះទេ



**The Cambodia Daily**

រីយ៉ាដ-រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកលោក ចន កែរី (Jonh Kerry) ដែលបានធ្វើដំណើរទៅកាន់ប្រទេសអារ៉ាប់ប៊ីសាអូឌីត ដើម្បីជួបពិភាក្សាជាមួយបណ្ដាមន្ត្រីមកពីប្រទេសឈូងសមុទ្រអារ៉ាប់បានមានប្រសាសន៍កាលពីម្សិលមិញថា ច្រកនៃឱកាសសម្រាប់ដំណោះស្រាយការទូតចំពោះបញ្ហានុយក្លេរអ៊ែររបស់ប្រទេសអ៊ីរ៉ង់"មិនអាចបើកចំហរគ្មានពេលកំណត់នោះទេ" ។

លោក ចន កែរី បានថ្លែងថា ក៏ប៉ុន្តែការចរចានឹងមិនបន្តឱ្យតែបាន១នោះទេ ហើយការចរចាក៏មិនអាចក្លាយជាឈ្នាន់មួយសម្រាប់ការពន្យាពេលដែលនឹងធ្វើឱ្យស្ថានភាពកាន់តែគ្រោះថ្នាក់នោះឡើយ" ។

ប្រមុខការទូតអាមេរិករូបនេះបានមានប្រសាសន៍ **តទៅទំព័រទី ០២**


## ដំណឹងជ្រើសរើសបុគ្គលិក

-ត្រូវការជ្រើសរើសបុគ្គលិកធ្វើការនៅ Galleria Mall ក្រុង New York សំរាប់ធ្វើក្រចក និងម៉ាស្សា ។

-កំរៃដែលអាចរកបានសំរាប់អ្នកធ្វើក្រចក $100 ទៅ 1300

-អ្នកធ្វើដៃជើងទឹក $600 ក្នុងមួយអាទិត្យ៦ថ្ងៃ អត់រាប់បញ្ចូល Tip ទេ មានកន្លែងទីស្នាក់អាស្រ័យនៅជិតកន្លែងធ្វើការ ។

-ត្រូវការមនុស្សអាចបើកបររថយន្តបានស្ទាត់ជំនាញ និងនិយាយភាសាអង់គ្លេសបានខ្លះ និងមានបទពិសោធន៍ស្ទាត់ជំនាញខាងធ្វើក្រចក និងកាសាច់ក្រចកធម្មតា និងម៉ាស្សាផងដែរ ។

ដាលីន : **(757) 771-5781** (និយាយភាសាខ្មែរ)
ឆាលី : **(848) 728-1577** (និយាយភាសាវៀតណាម)



## Collegiate Charter School of Lowell

**សាលារៀនអន្តរជាតិ និងបើកថ្មី បង្រៀន_សម្រាប់ទៅមហាវិទ្យាល័យ ផ្ដើមបើកនៅខែកញ្ញា ២០១៣ នេះហើយ ហើយផ្ដល់សេវាឱ្យសិស្សតាំងពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី៩**

## អនុវិទ្យាល័យ ឆាទើរ នៃក្រុងឡូវែល

**ផ្ដើមចុះឈ្មោះ ហើយ !**

- កម្មវិធីត្រៀមទៅវិទ្យាល័យ
- មានឯកសណ្ឋានសិស្ស
- បង្រៀនចរិយាសម្បត្តិ
- សង្កត់លើគណិតវិទ្យា និងអង់គ្លេសខ្លាំង
- ពេលរៀនច្រើនក្នុង១ថ្ងៃ
- ក្រមចរិយាមានច្បាស់លាស់
- មានក្ដីសង្ឃឹមខ្ពស់
- សាស្ត្រាចារ្យមានសញ្ញាប័ត្រខ្ពស់
- ការចូលរួមរបស់ឪពុកម្ដាយ
- កម្មវិធីកំសាន្តក្រៅយ៉ាងសប្បាយ
- កម្មវិធីមុននឹងក្រោយម៉ោងរៀន
- កន្លែងថ្មីស្អាត និងសុវត្ថិភាព
- ពង្រីកដល់សាលាដែលមានថ្នាក់ក៏រិត១២
- សិក្សាឥតយកតម្លៃជាសាធារណៈ



**ការិយាល័យចុះឈ្មោះ**
1857 Middlesex Street, Lowell, MA 01851
Phone: (978) 458-1399
E-mail: LCCS@sabis.net
www.LCCS.SABIS.net

*Member of the SABIS® School Network*

តមកពីទំព័រទី ១

# ចន ឃែរីថា ច្រកឱកាសសម្រាប់អ៊ីរ៉ង់មិនបើកចំហរ...

ទៀតថា រូបលោកនិងរដ្ឋមន្ត្រីក្រសួងការបរទេសអារ៉ាប៊ីតសាអូឌីត ព្រះអង្គម្ចាស់សាអ៊ូដអាលហ្វៃសាល(Saud al-Faisal) បាន "ពិភាក្សាអំពីការប្ដេជ្ញាចិត្តរួមគ្នាក្នុងការរារាំងអ៊ីងរ៉ង់មិនឱ្យមានអាវុធនុយក្លេអ៊ែរ" ។

ព្រះអង្គម្ចាស់ សាអ៊ូដ បានមានព្រះបន្ទូលថា ប្រទេសអារ៉ាប៊ីសាអូឌីត "គាំទ្រកិច្ចប្រឹងប្រែងដោះស្រាយវិបត្តិតាមផ្លូវការទូត



ចន ឃែរី និងភរិយា

ដើម្បីជម្រះរាល់មន្ទិលជុំវិញកម្មវិធីនុយក្លេអ៊ែររបស់ប្រទេសអ៊ីរ៉ង់" ។ ព្រះអង្គម្ចាស់មានបន្ទូលបន្ថែមថា "ម្ល៉ោះហើយហើយសង្ឃឹមថា ការចរចានឹងបានជាលទ្ធផលដោយការបញ្ចប់បញ្ហានេះជាជាងគ្រាន់តែរាំងខ្ទប់ស្ថានការណ៍" ហើយក៏ត្រូវពិចារណាផងដែរថា ទ្រនិចនាឡិកាចេះតែដើរទៅហើយ ហើយការចរចាមិនអាចបន្តរហូតនោះទេ" ។

ក្នុងដំណើរទស្សនិកនៅប្រទេសអារ៉ាប៊ីសាអូឌីត លោក ឃែរី ក៏នឹងពិភាក្សាជាមួយមេដឹកនាំរដ្ឋប៉ាឡេស្ទីនលោក ម៉ាមូដ អាបបាស (MahmoudAbbas) នៅទីក្រុងរ៉ាម៉ាដ ផងដែរ ។

ជំនួបរវាងលោក ឃែរី និងលោក អាបបាស កើតឡើងពីរសប្ដាហ៍មុនពេលលោកប្រធានាធិបតី ប៉ារ៉ាក់ អូបាម៉ា ទៅបំពេញទស្សនកិច្ចនៅប្រទេសអ៊ីស្រាអែលទឹកដីប៉ាឡេស្ទីន និងប្រទេសហ្ស៊កដានី ដើម្បីត្រួសត្រាយផ្លូវឱ្យមានការចាប់ផ្ដើមដំណើរការសន្តិភាពអ៊ីស្រាអែល-ប៉ាឡេស្ទីនវិញ ។

**ប្រធាននុយក្លេអ៊ែរ អ.ស.ប ជំរុញអ៊ីរ៉ង់ ដើម្បីចូលពិនិត្យទីតាំងយោធា**

វីយ៉េន-កាលពីម្សិលមិញ ប្រធានក្រុមឃ្លាំមើលនុយក្លេអ៊ែរអង្គការសហប្រជាជាតិបានជំរុញឱ្យប្រទេសអ៊ីរ៉ង់ឱ្យផ្ដល់សិទ្ធិចូលជាបន្ទាន់ដល់ក្រុមអធិការរបស់លោក ដើម្បីចូលទីតាំងយោធា ប៉ាឈីន ដែលនៅទីនោះ គេសង្ស័យថា ការសាកបំផ្ទុះពាក់ព័ន្ធនឹងការអភិវឌ្ឍន៍អាវុធនុយក្លេអ៊ែរប្រហែលជាបានធ្វើឡើង ។

អគ្គនាយកនៃទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ(JAEA) យូគីយ៉ា អាម៉ាណូ (Yukiya Amano) ប្រាប់ក្រុមប្រឹក្សាមាន៣៥ប្រទេសរបស់JAEAថា លោក "មិនអាចរាយការណ៍អំពីការវិវត្តន៍ណាមួយ" ក្នុងកិច្ចប្រឹងប្រែងតាំងពីរដើមឆ្នាំ២០១២មក ដើម្បីជម្រះកង្វល់អំពីកម្មវិធីនុយក្លេអ៊ែររបស់អ៊ីរ៉ង់បានទេ ។

JAEA ដែលមានមូលដ្ឋាននៅក្រុងវីយ៉េន បាននឹងកំពុងព្យាយាមជាងមួយឆ្នាំមកហើយ ដើម្បីបញ្ចុះបញ្ចូលប្រទេសអ៊ីរ៉ង់ឱ្យសហការជាមួយទីភ្នាក់ងារនេះ ក្នុងការស៊ើបអង្កេតដែលជាប់



តាំងជាយូរមកហើយអំពីកម្មវិធីស្រាវជ្រាវបរមាណូរបស់រដ្ឋអ៊ីស្លាមនេះដែលបដិសេធសកម្មភាពណាមួយបែបនេះ ។

លោក អាម៉ាណូ បាននិយាយថា ទីភ្នាក់ងារនេះ នៅតែប្ដេជ្ញាចូលរួមក្នុងការចរចាប្រកបដោយន័យស្ថាបនាជាមួយប្រទេសអ៊ីរ៉ង់ ប៉ុន្តែការចរចាត្រូវតែបន្ត "ក្នុងភាពបន្ទាន់ និងផ្ដោតលើលទ្ធផលជាក់ស្ដែងដែលទទួលបាន" ក្នុងពេលឆាប់ៗ ។

អាទិភាពរបស់ JAEA គឺដើម្បីអាចពិនិត្យ ប៉ាឈីន ជាទីតាំងដ៏ធំភាគអាគ្នេយ៍នៃរដ្ឋធានីតេហេរ៉ង់បានសាងសង់បន្ទប់ពិសោធន៍បំផ្ទុះ ដើម្បីធ្វើតេស្តប្រហែលមួយទសវត្សរ៍មកហើយ តែប្រទេសអ៊ីរ៉ង់បដិសេធរឿងនេះ ។ លោក អាម៉ាណូ បាននិយាយថា "ផ្ដល់សិទ្ធិចូល ប៉ាឈីន ជាជំហ៊ានវិជ្ជមានមួយដែលជួយបង្ហាញឆន្ទៈរបស់អ៊ីរ៉ង់ក្នុងការជម្រះកង្វល់របស់យើង" ៕

*ប្រែសម្រួលដោយ ប៉ុល មានិត*


Welcome សូមស្វាគមន៍

You're Cordially Invited! ពិធីសម្ពោធសមាគម ASALEC និង COVTA

NECC

New England Community Care

www.newenglandcommunitycare.com

ADULT DAY HEALTH CENTER





OPEN HOUSE

81 BRIDGE ST. LOWELL, MA 01852

MARCH 30,2013 TIME: 9:00 AM TO 3:00 PM

SENGHAP ROEUN 978-944-4182

HAPMISSION@GMAIL.COM

FREE EVENT

ENTERTAINMENT

REFRESHMENT

MARCH 30

TIME: 9:00 TO 3:00



ANGKOR DANCE TROUPE



KAO KANNIKA

# ខ្មែរអ្នកជាតិនិយម


និពន្ធដោយ ឡឹក សំអឿន ហៅ "ផ្កាយព្រឹក"

តពីលេខមុន

ខ្លួនជាកូនព្រះបាទអង្គច័ន្ទទី១នោះ ត្រូវបានពួកខ្មែរលើចូលរួបរួមផង បានបំបះបំបោរមហាជនចាប់តាំងពីខេត្តក្រចេះ រហូតមកដល់ឧត្តុង្គតែក្នុងរយៈពេល២ឆ្នាំប៉ុណ្ណោះ ។ ក្នុងការបង្ក្រាបចលនានាពេរកំបោរបារាំងបានហៅកងកម្លាំងអាណានិគមជាទាហានជើងក្រហមយួនក្រោមកិច្ចបញ្ជាការរបស់នាយទាហានបារាំងឱ្យមកជួយ ហើយបានចាប់ពោរកំបោរទៅកាត់កនៅខេត្តកំពង់ធំ ។

ក្នុងពេលជំណាលគ្នានោះ ដើម្បីកុំឱ្យសៀមលូកដៃចូលទៅជួយក្រុមចលនាបះបោរ និងគោរពកិច្ចសន្យារបស់ខ្លួននោះបារាំង និងសៀមបានចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង-សៀមមួយនៅក្រុងបារីសក្នុងឆ្នាំ១៨៦៧ ។ នៅក្នុងសន្ធិសញ្ញានោះនិយាយថាសៀមឈប់ទាមទារសួយសារអាករខ្មែរ ប៉ុន្តែបារាំងត្រូវប្រគល់ខេត្តសៀមរាប.បាត់ដំបង.ស្រីសោភ័ណ.ទន្លេរពៅ. និងមូលព្រៃក្នុងខេត្តកំពង់ធំឱ្យទៅសៀម ។ នៅឆ្នាំដដែលនោះបារាំងវាយយកបានខេត្ត៣ទៀតនៅកម្ពុជាក្រោម គឺខេត្តវិញឡើង.ស្រុកទ្រាំង និងមាត់ជ្រូក(ចូវដុក) ។ ចំណែកឯការវាយយកអណ្ណាមពេលនោះបារាំងគ្មានឧបសគ្គសោះឡើយ ព្រោះអធិរាជ ទឹឌឹក បានស្លាប់តាំងពីខែកក្កដា ឆ្នាំ១៨៨៣ ម្ល៉េះ យួនពុំបានធ្វើការទប់ទល់ទេ ហើយនៅថ្ងៃទី២៥ សីហា ១៨៨៣ យួនបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយទទួលយកការគាំពារពីប្រទេសបារាំងលើអណ្ណាម ក៏ប៉ុន្តែការវាយយកតុងកឹងបារាំងមានបញ្ហាដោយមានអន្តរាគមន៍ពីប្រទេសចិន ។

នៅឆ្នាំ១៨៨៤ ប្រទេសបារាំងបានបង្ខំឱ្យប្រទេសខ្មែរឱ្យចូលផ្សាររួមម្យ៉ាង ដែលបំបាត់ចោលនូវការយកពន្ធដារ និងគយរវាងកម្ពុជា. អណ្ណាម និងកូសាំងស៊ីន ក្នុងគោលបំណងនាំយកវត្ថុធាតុដើមពីកម្ពុជា ចូលទៅកូសាំងស៊ីនបានដោយស្រួល ដើម្បីលើកតម្កើងសេដ្ឋកិច្ចយួនឱ្យរុងរឿង ។

បន្ទាប់ពីការមិនយល់ព្រមនៃព្រះបាទនរោត្តមមកនោះ ស្ហាលស៍ តុមសុន (Charles Thomson) ដែលជាទេសាភិបាលបារាំងប្រចាំកូសាំងស៊ីនបានលើកទ័ពដោយមាននាវាចម្បាំង៣គ្រឿងផ្ទុកកាំភ្លើងធំ ចុះមកពីព្រៃនគរមកសំចតនៅទន្លេមេគង្គជិតឧត្តុង្គ ។ នៅពេលដែលនាវាទាំង៣គ្រឿងកំពុងតម្រង់កាំភ្លើងធំទៅរាជវាំងឧត្តុង្គតុមសុនព្រមទាំងទាហានគាត់៥-៦នាក់ ក៏សម្រុកចូលព្រះរាជវាំងគំរាមកំហែងព្រះបាទនរោត្តមដោយចំពុះទុង ភ្លង់ក រួចស្រែក សំឡុតថា នឹងបំបរបង់ប្រសិនបើទ្រង់មិនព្រមប្រឡាយព្រះហស្ថលើសន្ធិសញ្ញាមួយដែលធ្វើកម្ពុជាក្លាយទៅជាអាណានិគមបារាំង ។ ពេលនោះដោយចាញ់សំឡុតបារាំងនរោត្តមក៏ស៊ីញ៉េខ្ទោកយល់ព្រមកែទម្រង់រដ្ឋាភិបាល. ហិរញ្ញវត្ថុ និងពាណិជ្ជកម្មគ្រប់យ៉ាង តាមតែបារាំងយល់ថា មានប្រយោជន៍ដល់ប្រទេសជាតិ ជាពិសេស គឺការលុបបំបាត់ចោលនូវទាសភាព។

នៅដើមឆ្នាំ ១៨៨៥ ការប្រកួតប្រជែងគ្នាដើម្បីដណ្តើមយករាជបល្ល័ង្កនៃអង្គម្ចាស់ ស៊ីវុត្ថាដែលជាប្អូនបង្កើតរបស់នរោត្តមបានក្លាយទៅជាសង្គ្រាមឆ្អក់តទល់ប្រឆាំង និងអាណាព្យាបាលបារាំង ។ រហូតដល់ឆ្នាំ១៨៨៧ ទើបស៊ីវុត្ថារំដោះបានតំបន់មួយ ហើយបង្កើតជារាជាណាចក្ររបស់ខ្លួនក្នុងភូមិភាគកំពង់ស្វាយខេត្តកំពង់ធំ ។ ដោយព្រួយបារម្ភក្រែងសៀមលូកដៃចូលជួយស៊ីវុត្ថាបារាំងក៏ជ្រើសរើសយកកិច្ចចរចាបញ្ចប់សង្គ្រាមដោយប្រើល្បិចកលទម្លាប់នរោត្តមពីរាជបល្ល័ង្ករួចយកស៊ីវុត្ថាជំនួសវិញ ប៉ុន្តែនៅពេលចរចាទៀបនឹងចប់ម្ចាស់ស៊ីវុត្ថាក៏បានចូលទិវង្គតទៅ ហើយចលនាតស៊ូក៏រលត់រលាយអស់ ។

ពេលដែលកម្ពុជាបានស្ងប់ហើយ បារាំងក៏ចាប់ផ្តើមគំនិតថ្មីមួយទៀតវាយយកតុងកឹងដោយប្រើល្បិចវាយបំភ័ន្តចិននៅលើកោះហ្វ័រម៉ូសព្រមទាំងលើកោះអេស្កាឌរ ទើបចិនឈប់ធ្វើអន្តរាគមន៍លើតុងកឹង ហើយនៅថ្ងៃទី២ មិថុនា ១៨៨៥ ចិនដែលចាញ់បញ្ឆោតបារាំងក៏បានចុះហត្ថលេខាលើសន្ធិសញ្ញាជិនស៊ិនទទួលស្គាល់អាណាព្យាបាលបារាំងលើអណ្ណាម និងតុងកឹង ។ ក្រោយពីយកបានកម្ពុជា.កូសាំងស៊ីន.តុងកឹង និងអណ្ណាម ហើយបារាំងក៏ចាត់វិធានការណ៍រឹបអូសអំណាចទាំងអស់ភ្លាម ដើម្បីទាញយកកំរៃធនធានរ៉ែ និងធនធានកសិកម្មពីប្រទេសដែលនៅក្រោមអាណាព្យាបាលរបស់ខ្លួនហើយឱ្យឈ្មោះថា "ទ្រព្យសម្បត្តិអាណានិគម" ។ ដើម្បីញ៉ាំងវិធានការណ៍នេះឱ្យសម្រេចបារាំងបានរៀបចំរចនាសម្ព័ន្ធជាចាំបាច់ ។ គឺបង្ហាត់ហ្វឹកហ្វឺនជនជាតិយួនឱ្យចូលជាក្របខណ្ឌដើម្បីឱ្យជួយបំពេញបេសកម្មនេះ ព្រោះឃើញថាយួនជាជនជាតិមួយថ្មីដែលទើបវាយដណ្តើមយកបានទឹកដីក្នុងភូមិភាគនេះ យួនជាអ្នកឈ្នះលើប្រទេសជិតខាងជាជនជាតិមានចំណេះចេះដឹងឈ្លាសវៃឧស្សាហ៍ តទៅលេខក្រោយ

NEW ENGLAND INSTITUTE OF HVAC, Inc.
វិទ្យាស្ថានបណ្តុះបណ្តាលជំនាញខាងបង្រៀនពី
ម៉ាស៊ីនកំដៅ, ម៉ាស៊ីនត្រជាក់ និងទូរទឹកកក
ថ្នាក់រៀនពេលថ្ងៃ និងពេលល្ងាច និងផ្តើមឆាប់ៗនេះ
បំពេញការសិក្សាបច្ចេកទេសខាងម៉ាស៊ីនត្រជាក់
ម៉ាស៊ីនកំដៅ ទូរទឹកកក HVAC គឺសិក្សា
តែរយៈពេល១៣សប្តាហ៍
• សិក្សាដោយពិសោធន៍ផ្ទាល់ដៃ • ជួយរកការងារធ្វើ
• ផ្តល់សម្ភារៈឱ្យ • ថ្នាក់រៀនសិស្សតិច
• GI Bill Education Benefits Approved
• Section 30 Approved



NATE Certifications NATE,
EPA Testing,
OSHA, and Financing Available
to those who qualify
គឺជាប្រភពសម្រាប់ថាមពលបៃតង
Call for details: 978.735.4979
NEW ENGLAND INSTITUTE OF HVAC, INC
240 Smith St., Lowell, MA 01851
www.newenglandhvac.com

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
•សេចក្តីគ្រោះថ្នាក់ដល់រូបរាងកាយ
•ពិការភាពដោយសន្តិសុខសង្គម •គ្រោះថ្នាក់ចរាចរណ៍
•បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន •គ្រោះថ្នាក់នៅការដ្ឋាន
•ច្បាប់គ្រួសារ និងលែងប្តីប្រពន្ធ
•បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
•Personal Injury •Family Law & Divorce
•Disability •Traffic Accidents
•Sex & Drug Crimes, OUI •Work Accidents
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

# អ្នកក្រ និងអ្នកមាននៅប្រទេសខ្មែរ ភាគទី៦



គីម សុស មន្ត្រីចូលនិវត្តក្រសួងការបរទេសសហរដ្ឋអាមេរិក

គីម សុស

ធម្មតាមនុស្សចង់បានសេចក្តីចម្រើនអ្នកក្រចង់មានអ្នកមានចង់មានឡើង។

តើរាជរដ្ឋាភិបាលអាចជួយតាមរបៀបណាដើម្បីឱ្យសម្រេចគោលបំណងនេះបាន?

លោកកែមឡី អ្នកតាមដានសេដ្ឋកិច្ចខ្មែរនៅដើមខែកុម្ភៈឆ្នាំ២០១៣ តាមវិទ្យុអាស៊ីសេរីមានប្រសាសន៍ថា នៅប្រទេសខ្មែរមានឧកញ៉ាយ៉ាងតិច២២០នាក់ឥឡូវនេះ។

ដូច្នេះឃើញថា ក្នុងចំនួនប្រជាពលរដ្ឋជាង១៤លាននាក់នៅប្រទេសខ្មែរ មានមហាសេដ្ឋី២២០នាក់ គឺថា ក្នុងប្រជាពលរដ្ឋប្រមាណមួយសែននាក់មានមហាសេដ្ឋីជិតពីរនាក់។ ដើម្បីឱ្យស្រួលចាំយើងគិតថា ឥឡូវនេះក្នុងមួយសែនអ្នកមានអ្នកមានពីរនាក់ ។ ដូច្នេះគួរគិតថា ធ្វើយ៉ាងម៉េចក្នុងរវាង១០ឆ្នាំទៀតក្នុងពលរដ្ឋមួយពាន់នាក់ឱ្យមានអ្នកមានពីរនាក់ គឺថាក្នុងប្រជាពលរដ្ឋ១៤លាននាក់ជាងមានអ្នកមានពីរម៉ឺនប្រាំបីពាន់នាក់។ នេះមានន័យថាចំនួនអ្នកមានឡើងមួយរយដង។ ទៅរួចទេ?

តាមការសង្កេត ចំនួនអ្នកមាននៅប្រទេសខ្មែរកើនឡើងមិននៅនឹងទេ បើយោងតាមល្បឿនសេដ្ឋកិច្ចឡើងប្រមាណ៧ភាគរយជាមធ្យមពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែគ្មានការដឹងច្បាស់ថាកើនឡើងប៉ុន្មាននោះទេក្នុងមួយឆ្នាំៗ។ ប៉ុន្តែយ៉ាងណាក៏ដោយ សភាពការណ៍សេដ្ឋកិច្ចនេះធ្វើឱ្យមានសង្ឃឹមក្នុងការបង្កើនការងារ។

ហើយចំនួនឧកញ៉ាមហាសេដ្ឋីចំនួនពីរនាក់ក្នុងចំនួនមួយសែននាក់នេះ ក៏ជាសញ្ញាបង្ហាញក្តីសង្ឃឹមមួយថែមទៀតថា អាចជួយបង្កើតឱ្យមានការងារបានច្រើន។ ទាំងអស់ធ្វើឱ្យមានសង្ឃឹមថា ចំនួនអ្នកមានកាន់តែកើនច្រើនឡើង ច្រើនឡើង។

ប៉ុន្តែទោះជាមានការចម្រើនក្នុងការបង្កើតការងារយ៉ាងនេះក៏ដោយ ក៏ចំនួនអ្នកអត់ការធ្វើកាន់តែកើនឡើងហើយចំនួនអ្នកក្រក៏កាន់តែកើនឡើងដែរ។

ដូច្នេះក្នុងចំណុចនេះមានបញ្ហាពីរដែលត្រូវដោះស្រាយ។ ជាគោលដៅមួយគឺបង្កើតចំនួនការងារឱ្យបានស្មើរ នឹងចំនួនអ្នករកការងារធ្វើ។ ហើយមួយទៀតគឺប្រែភាពក្រីក្រ ឱ្យទៅជាភាពមាន។

តើសម្រេចគោលដៅនេះយ៉ាងដូចម្តេចបាន? ក្នុងដំណើរទៅកាន់ការសម្រេចគោលដៅនេះ រដ្ឋាភិបាលអាចជួយបានច្រើន។ យើងដឹងអ្នកជំនួញតែងតែចង់ចំណេញ កាលណាចំណេញច្រើនធ្វើឱ្យឆាប់មានកាលណាមានច្រើនធ្វើឱ្យចង់មានថែមទៀត នេះជាចរន្តបណ្តាលឱ្យមុខរបរនីមួយៗកាន់តែរីក ហើយចំនួនក៏កាន់តែច្រើនដែរ។ ដូច្នេះចំនួនការងារក៏កាន់តែកើនច្រើនឡើងដែរ។ នេះជាគំនិតគន្លឹះ។

ក្នុងករណីនេះ ដ្ឋាភិបាលត្រូវតែគិតថាធ្វើយ៉ាងម៉េចឱ្យអ្នកជំនួញឆាប់បានចំណេញច្រើនឆាប់មាន។ តើត្រូវធ្វើយ៉ាងដូចម្តេចខ្លះ?កន្លែងខ្ញុំតែងតែឮអ្នកធ្វើជំនួញនិយាយថាកត្តាបីដែលធ្វើឱ្យជំនួញចម្រើនគឺ កន្លែង កន្លែង និងកន្លែង។ ត្រង់នេះ រដ្ឋាភិបាលអាចជួយបានច្រើន។ រដ្ឋាភិបាលគួរស្រាវជ្រាវរកកន្លែងមូលដ្ឋានពាណិជ្ជកម្មក្នុងតំបន់ទូទាំងប្រទេស។ គោលដៅគឺបង្កើតការងារឱ្យបានច្រើនហើយឆាប់រហ័ស។

តាមស្ថិតិនៅសហរដ្ឋអាមេរិក ជំនួញខ្នាតតូចនិងខ្នាតមធ្យមបង្កើតការងារបានច្រើនហើយលឿន ហើយញ៉ាំងឱ្យសេដ្ឋកិច្ចចម្រើនរហ័សដែរ។ ដូច្នេះរដ្ឋាភិបាលគួរផ្តោតទៅលើមូលដ្ឋានជំនួញខ្នាតតូចនិងខ្នាតមធ្យមឱ្យបានច្បាស់លាស់ជាទីបំផុត ហើយធ្វើយ៉ាងម៉េចឱ្យបានចំនួនជំនួញខ្នាតតូចនិងខ្នាតមធ្យមច្រើនជាទីបំផុត។

ឧទាហរណ៍សព្វថ្ងៃនេះ ខ្វះផ្សារច្រើណាស់។ ដូចជានៅភ្នំពេញជាដើម ផ្សារចាស់ ផ្សារកណ្តាល ផ្សារថ្មី ផ្សារស៊ីឡឹប ផ្សារទឹកល្អក់ ផ្សារទួលទំពូង និងផ្សារឯទៀតនៅភ្នំពេញ ចង្អៀតហើយក្រខ្វក់។ ផ្សារនីមួយៗនោះ គួរតែចជាពីរ ឬជាបី។ ហើយផ្សារទាំងអស់នៅទីរួមខេត្ត និងទីរួមស្រុកក៏ត្រូវតែចែកដែរ ព្រោះចង្អៀតហើយក្រខ្វក់។

មានកន្លែងឯទៀតសម្រាប់បង្កើតផ្សារបានច្រើនទៀត។ នៅតាមដងផ្លូវធំៗទូទាំងប្រទេសជាពិសេសតាមផ្លូវចេញពីភ្នំពេញទៅខេត្ត នៅម្តុំភូមិមានប្រជាជនកសិករច្រើន គួរមានផ្សារសម្រាប់កសិករលក់ផលដំណាំរបស់ខ្លួន ដូចជាបន្លែផ្លែឈើ គ្រឿងម្ហូបអាហារ ពងមាន់ពងទាត្រីសាច់ជាដើម។

កន្លែងឯទៀតដែលរដ្ឋាភិបាលគួគិតគឺកន្លែងសម្រាប់ទាក់ទាញទេសចរ ។ កន្លែងទាំងនោះជាកន្លែងសម្រាប់កំសាន្តរំហែចិត្តរំហែកាយ ។ ដូច្នេះកន្លែងទាំងនោះត្រូវការមានសណ្ឋាគារ ភោជនីយដ្ឋាន សួនច្បារ និងអ្វីឯទៀតសម្រាប់ទាក់ទាញទឹកចិត្តមនុស្ស ។ នៅប្រទេសខ្មែរ ក្រៅពីសៀមរាបអង្គរមានកន្លែងច្រើនទៀត ដូចនៅក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី បាត់ដំបង ភ្នំពេញ កែប កំពត ព្រះសីហនុ កោះគង់ និងតាមដងព្រៃមាត់បឹងមាត់ទន្លេឆ្នេរសមុទ្រជាដើម។

តាមយោបល់ខ្ញុំ ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីសង្កេតឱ្យឃើញកន្លែងពាណិជ្ជកម្មសម្រាប់ទាក់ទាញទឹកចិត្តមនុស្ស។ គោលគំនិតដែលភ្ជាប់ឱ្យជាប់គឺ បង្កើនសេដ្ឋកិច្ច ។ ឧទាហរណ៍នៅកែបកន្លែងដែលសង់អាគារសាលាក្រុងគួរតែជាកន្លែងសម្រាប់សណ្ឋាគារ ភោជនីយដ្ឋានសាលមហោស្រព **តទៅទំព័រទី១២**


GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)






DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.

WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

www.gatewayfamilydental.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំណឹងប្រែសម្រួលពីកាសារអង់គ្លេស　　អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី　　ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី០៥ ខែ មិនា ឆ្នាំ២០១៣

## ក្រុមអ្នកបកប្រែនៅសាលាក្ដីខ្មែរក្រហមបន្ត ធ្វើកូដកម្មដោយសារមិនទាន់ទទួលបានប្រាក់ខែ

*Lauren Crothers*

**ខេមបូឌា ដេលី**

កាលពីម្សិលមិញបុគ្គលិកជាតិមកពីអង្គភាពបកប្រែភាសានៅសាលាក្ដីខ្មែរក្រហមបានធ្វើកូដកម្ម ហើយបាននិយាយថា ពួកគេនឹងមិនចូលធ្វើការវិញទេ លុះណាតែខ្លួនទទួលបានប្រាក់ខែសិន ។ ការតវ៉ានេះធ្វើឱ្យតុលាការមិនអាចបន្តនិតិវិធីរបស់ខ្លួនបានឡើយ ។

កូដកម្មនេះជាលើកទី១ហើយ ក្នុងប្រវត្តិសាស្ត្ររបស់សាលាក្ដីដែលបានប្រកាសថា សវនាការជំនុំជម្រះនឹងចាប់ផ្ដើមអមដោយការបកប្រែផ្ទាល់ពីភាសាខ្មែរទៅភាសាអង់គ្លេស និងទៅជាភាសាបារាំង ហើយបុគ្គលរបស់អង្គភាពបកប្រែបានប្រកាសថា ខ្លួននឹងធ្វើកូដកម្មរហូតទទួលបានប្រាក់ខែដែលមិនទាន់បានបើកបីខែមកហើយ ។

ក្រុមអ្នកតវ៉ាបានស្រែកតាមប្រព័ន្ធឧត្បោសនសព្ទដោយសំដៅចំពោះលោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង "នេះជាភាសារបស់ក្រុមបកប្រែជូនចំពោះលោកប្រធាន ។ លោកប្រធាន និងភ្ញៀវកិត្តិយសព្រមទាំងគូភាគីទាំងអស់ជាទីគោរព យើងជាបុគ្គលិករបស់អង្គភាពបកប្រែភាសានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឥឡូវនេះយើងកំពុងពហិការមិនចូលទៅធ្វើការវិញឡើយ លុះណាតែពួកយើងទទួលបានប្រាក់ខែក្នុងខែធ្នូឆ្នាំ២០១២ប្រាក់ខែក្នុងខែមករា និងកុម្ភៈ ឆ្នាំ២០១៣ សិន" ។

យោងតាមសំដីក្រុមអ្នកបកប្រែម្នាក់ដែលបាននិយាយតាងនាមឱ្យសមភាគីជាតិរបស់ខ្លួនបានឱ្យដឹងថា ចៅក្រមរបស់អង្គជំនុំជម្រះបានកោះប្រជុំភ្លាមៗ ដើម្បីសម្រេចថា តើត្រូវបន្តនិតិវិធីដោយគ្មានជំនួយពីក្រុមបកប្រែបានដែរឬទេ។ ក្នុងរយៈពេល៤៥នាទីក្រោយមកសវនាការជំនុំជម្រះបានបន្ត ប៉ុន្តែក្រុមបកប្រែបានប្រាប់តុលាការថា ខ្លួននឹងបន្តធ្វើកូដកម្មកន្លះម៉ោងទៀតពីព្រោះ"បន្ទាប់ពីនោះ ខ្លួននឹងមិនបន្តធ្វើការតវ៉ាទៀតទេ" ។

មិនពេលបញ្ឈប់នីតិវិធី ចៅក្រមបានប្រាប់អង្គសវនាការថា សហចុងចោទ គឺលោក អៀង សារី បានចូលសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យនៅព្រឹកនេះ ហើយថា លោក ហ្វីលីព សត ជាអ្នកត្រូវផ្ដល់សក្ខីកម្មដ៏សំខាន់ដែលគ្រោងនិយាយប្រាប់តុលាការ កាលពីម្សិលមិញ លោកនឹងត្រូវពន្យាពេលមកចូលរួម ។

បុគ្គលិកជាតិរបស់សាលាក្ដីបាននឹងកំពុងគំរាមកំហែងធ្វើកូដកម្មចាប់តាំងពីខែមករាមកជុំវិញវិបត្តិហិរញ្ញវត្ថុធ្ងន់ដែលបុគ្គលិកភាគច្រើនមិនទទួលបានប្រាក់ខែចាប់តាំងពីខែ វិច្ឆិកាមក ។ ពួកគេបាននឹងកំពុងធ្វើការដោយគ្មានកិច្ចសន្យាការងារចាប់តាំងពីដើមឆ្នាំនេះមក ។

ពេលមានប្រសាសន៍តាមទូរស័ព្ទដោយមិនបញ្ចេញឈ្មោះ ហើយភ្លាមៗនោះបុគ្គលិករបស់អង្គភាពបកប្រែត្រូវបានកោះហៅឱ្យទៅជួបប្រជុំជាមួយផ្នែកគ្រប់គ្រងបន្ទាប់ពីសវនាការត្រូវបានផ្អាកដែលអ្នកបកប្រែម្នាក់ក្នុងចំណោមអ្នកបកប្រែជាតិនៅតុលាការនេះមានប្រសាសន៍ថា បុគ្គលិកប្រហែល៣០នាក់មកពីអង្គភាពបកប្រែនេះសម្រេចថា ពួកគេគ្មានជម្រើសអ្វីក្រៅពីធ្វើកូដកម្មឡើយ ។

ក្រុមអ្នកបកប្រែនិយាយថា "យើងមានការព្រួយបារម្ភដូចគ្នា ។ យើងនឹងមិនត្រឡប់ទៅធ្វើការវិញទេ ប្រសិនបើគេមិនឆ្លើយតបតាមការទាមទាររបស់យើងទេនោះ" ។

លោកបានលើកឡើងថា បុគ្គលិកមកពីអង្គភាពបកប្រែមានការសង្ស័យចំពោះការិយាល័យរដ្ឋបាលរបស់សាលាក្ដីយូរណាស់មកហើយ និងមានអារម្មណ៍ថា គេចេះតែសន្យាឱ្យរួចពីមាត់ថាពួកខ្លួននឹងទទួលបានប្រាក់ខែ ប្រសិនបើបន្តរង់ចាំ" ។

អ្នកបកប្រែរូបនេះបានឱ្យដឹងដែរថា "ត្រង់ចំណុចមកដល់ពេលនេះយើងទាំងអស់ធ្លាប់បានអត់ធ្មត់ និងទន់ភ្លន់ខ្លាំងណាស់ ប៉ុន្តែខ្ញុំគិតថាការអត់ធ្មត់របស់យើងមានព្រំដែនកំណត់ ដូច្នេះយើងមិនអាចបន្តធ្វើការក្នុងរយៈពេលបីខែទៀតដោយគ្មានកិច្ចសន្យាការងារនោះទេ ។ ខ្ញុំមិនឃើញមានហេតុផលសមរម្យដើម្បីឱ្យបុគ្គលិកបន្តធ្វើការទៀតទេ" ។

អ្នកបកប្រែរូបនេះបន្ថែមថា "ការិយាល័យរដ្ឋបាល ដែលមានលោក ក្រាញ់ តូនី ជា ប្រធានស្ដីទីកំពុងរកវិធីដាក់សម្ពាធមកលើពួកយើង និងបំភិតបំភ័យពួកយើង ដើម្បីឱ្យយើងទ្រាំនៅស្ងៀមពីរបីសប្ដាហ៍ ឬរាប់ខែទៀត" ។

អ្នកបកប្រែក៏បានលើកឡើងផងដែរថា ការប្រជុំកាលពីម្សិលមិញ គឺជាការប្រជុំលើកទី១ដែលលោក ក្រាញ់ តូនី បានជួបដោយផ្ទាល់ជាមួយបុគ្គលិកតវ៉ានេះ ។

លោកបានបន្តថា បន្ទាប់ពីមានការស្នើសុំឱ្យត្រឡប់ទៅធ្វើការវិញនៅក្នុងកិច្ចប្រជុំនាព្រឹកនោះ បុគ្គលិករបស់អង្គភាពបកប្រែក៏បានជួបពិភាក្សាជាមួយតំណាងមកពីការិយាល័យរដ្ឋ

**តទៅទំព័រទី ១៦**

## និយោជិតក្រុមហ៊ុនអឹមហ្វូនទាមទារប្រាក់ខែ ដែលក្រុមហ៊ុនក្ស័យធនមួយនេះមិនទាន់បើកឱ្យ

**អួន ពាភ**

**ខេមបូឌា ដេលី**

កាលពីម្សិលមិញ និយោជិតចំនួន១០០នាក់របស់ក្រុមហ៊ុនបំរើសេវាទូរស័ព្ទចល័តក្ស័យធនមួយ គឺក្រុមហ៊ុនអឹមហ្វូន (Mfone) បាននាំគ្នាមកតវ៉ានៅខាងក្រៅទីស្នាក់ការក្រុមហ៊ុនដែលត្រូវបានបិទទ្វារនៅរាជធានីភ្នំពេញដោយបានទាមទារថា ពួកគាត់បានធ្វើការឱ្យក្រុមហ៊ុន បើទោះបីជាក្រុមហ៊ុនអឹមហ្វូនបានឈប់ធ្វើអាជីវកម្មហើយក៏ដោយ ។

ការតវ៉ានេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការតែងតាំងអ្នកគ្រប់គ្រងរដ្ឋបាលម្នាក់ ដែលត្រូវជ្រើសរើសដោយសាលាដំបូងរាជធានីភ្នំពេញដើម្បីឱ្យមកគ្រប់គ្រងលើដំណើរការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនអឹមហ្វូន ហើយអ្នកគ្រប់គ្រងរដ្ឋបាលរូបនេះបានប្រកាសជាសាធារណថាក្រុមហ៊ុនឈប់បើកប្រាក់ខែឱ្យបុគ្គលិកទាំងអស់ចាប់ពីថ្ងៃទី១ ខែកុម្ភៈ ។

លោក ម៉ា សាមឿន អាយុ៦២ឆ្នាំ ជាបុគ្គលិករដ្ឋបាលរបស់ក្រុមហ៊ុនអឹមហ្វូនដែលបានចូលរួមក្នុងការតវ៉ានេះមានប្រសាសន៍ថា គាត់បានចូលធ្វើការជាមួយក្រុមហ៊ុននេះអស់រយៈពេល១៩ឆ្នាំមកហើយ ហើយថា រូបគាត់ និងបុគ្គលិកជិត១២០០នាក់ទៀត ដែលធ្វើការនៅរាជធានីភ្នំពេញ និងនៅតាមខេត្តកំពុងទាមទារក្រុមហ៊ុនអឹមហ្វូនឱ្យបើកប្រាក់ខែសម្រាប់ខែកុម្ភៈឱ្យពួកគាត់ ។

លោកបានមានប្រសាសន៍ថា "ឥឡូវនេះខ្ញុំចាស់ហើយ ហើយពិតជាមិនអាចទៅស្វែងការងារផ្សេងទៀតបានទេ ដូច្នេះខ្ញុំត្រូវការប្រាក់ខែ ខែចុងក្រោយជាចាំបាច់ ដើម្បីចិញ្ចឹមគ្រួសាររបស់ខ្ញុំ" ។

កាលពីខែមុនក្រុមហ៊ុនស្មាតម៉ូបាយ (Smart Mobile) ដែលគ្រប់គ្រងដោយក្រុមហ៊ុនឡេតថែល ខូអិលធីឌី (Latelz) មានមូលដ្ឋាននៅប្រទេសស៊ីបបាន **តទៅទំព័រទី ២០**

## Mfone Employees Demand Unpaid Salaries

**By Aun Pheap**

**THE CAMBODIA DAILY**

More than 100 former employees of the bankrupt mobile telephone company Mfone protested outside the firms´ shuttered office in Phnom Penh yesterday, demanding that they receive salaries for working the month of February despite the company having already gone out of business.

The protest followed the appointment of an administator, nominated by the Phnom Penh Municipal Court to oversee the liq uidation of Mfone´s assets, who posted an announcement stating that workers´ salaries had officially stopped being paid from February 1.

Mar Samoeun, 64, an admini strative worker for Mfone who took part in the protest, said he had been at the company for 19 years and that he and nearly 1,200 staff working in Phnom Penh and in the privince were asking that Mfone pay them for month of Februray.

"I am old now and can not really find another job, so I need my last payment of feed my family," he said.

Last month, Smart Mobile, which is owned by the Cyprusbased Latelz Co. Ltd., filed a court complaint to collect unpaid bills from Mfone. Chinese telecommunications firm Huawei Technologies Co. Ltd. has submitted a complaint alleging that Mfone owes more that $65 million in unpaid bills and Norwegian- owned Eltek claims it is owed $3. 73 million.

The municipal court issued two injunctions, one on October 18 and another on January 17, in order to prevent Mfone from selling its assets. However, the company in January transterred it roughly 400, 000 mobile phone subscribers to local phone operator Mobitel a move the companies who have filed against Mfone say flouts the court´s injunctions.

Staff and management from Mfone met with offcials at the Ministry of Labor yesterday in order to try and find a solution to the dispute over salaries.

Vong Savan, deputy secretary general of the labor conflict commission at the Ministry of Labor, said that Mfone staff had originally demanded 75 percent of their pay since work stopped at the company in Januray. However, they agreed yesterday to lower their demands to 50 percent.

Nim Solida, a representative for Mfone, said the company would meet the workers´ demands to receive 50 percent of their wages.

"We agreed with the resolution of 50 percent and included some other advantages," he said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី០៥ ខែ មិនា ឆ្នាំ២០១៣

# សំណុំរឿង ឈូក បណ្ឌិត ត្រូវបង្វែរទៅឱ្យ សាលាដំបូងខេត្តស្វាយរៀងវិញ

**ឃី សុវុឌ្ឍី**

**ខេមបូឌា ដេលី**

កាលពីម្សិលមិញសាលាឧទ្ធរណ៍បានបញ្ជូនសំណុំរឿងលោក ឈូក បណ្ឌិត អតីតអភិបាលក្រុងបាវិតដែលរងការចោទប្រកាន់ពីបទបង្ករបួសស្នាមដោយអចេតនាទៅឱ្យសាលាដំបូងខេត្តស្វាយរៀងវិញ ។ លោក ឈូក បណ្ឌិត ត្រូវបានចោទប្រកាន់ពីបទបាញ់កម្មការិនីរោងចក្រកាត់ដេរបីនាក់ អំឡុងការតវ៉ាមួយនៅខាងក្រៅរោងចក្រផលិតស្បែកជើងកីឡាក្នុងក្រុងបាវិតកាលពីឆ្នាំមុន ។

ប៉ុន្តែអង្គការសិទ្ធិមនុស្សមួយចំនួនបានរិះគន់ចៅក្រមចំនួន៣រូបនៅសាលាឧទ្ធរណ៍ ចំពោះការបញ្ជូនសំណុំរឿងនេះត្រឡប់ទៅសាលាដំបូងខេត្តស្វាយរៀងវិញ ជាតុលាការដែលបានលើកលែងការចោទប្រកាន់ពីបទបាញ់ប្រហាររបស់លោក ឈូក បណ្ឌិត ដោយគ្មានហេតុផលច្បាស់លាស់ កាលពីខែធ្នូ ទោះបីជាសាក្សីដែលបានឃើញផ្ទាល់ភ្នែកបញ្ជាក់ថា អតីតអភិបាលក្រុងរូបនេះ គឺជាខ្មាន់កាំភ្លើងតែម្នាក់ក៏ដោយ ។

នៅពេលបើកសវនាការជំនុំជម្រះរឿងក្ដីនេះ កាលពីសប្តាហ៍មុនសាលាឧទ្ធរណ៍កាលពីម្សិលមិញ បានរាំងសាធារណជនម្ដងទៀត មិនឱ្យចូលរួមក្នុងសវនាការនេះឡើយ ដោយលើកហេតុផលថា ការបើកសវនាការជំនុំជម្រះក្ដីនេះគ្រាន់តែជាផ្នែកមួយនៃការស៊ើបអង្កេតដែលកំពុងតែបន្តប៉ុណ្ណោះ មិនមែនជាការកាត់ក្ដីឡើយ ។ ប៉ុន្តែបន្ទាប់ពីបានចាកចេញពីបន្ទប់សវនាការលោក ឃុន លាងម៉េង ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានឈប់មួយសន្ទុះ ដើម្បីរៀបរាប់ដោយខ្លីប្រាប់អ្នកយកព័ត៌មានអំពីសេចក្ដីសម្រេចរបស់លោកក្នុងការចោទប្រកាន់មន្ត្រីរដ្ឋាភិបាលរូបនេះឡើងវិញ ។

លោកបានមានប្រសាសន៍ថា "តុលាការសម្រេចចោទប្រកាន់លោក ឈូក បណ្ឌិត ពីបទបង្ករបួសស្នាមដោយអចេតនា និងបានបញ្ជូនសំណុំរឿងនេះទៅឱ្យសាលាដំបូងខេត្តស្វាយរៀងផ្ដន្ទាទោសច្បាប់វិញ" ។

ដោយស្ថិតនៅក្នុងការស៊ើបអង្កេតលោកចៅក្រម លាងម៉េង **តទៅទំព័រទី ១៤**

# Bundith Ordered to Stand Trial for Triple Shooting

B Y KHY SOVUTHY

THE CAMBODIA DAILY

The Appeal Court yesterday reinstated the charge of causing unintentional injury against Chhouk Bundith, the former governor of Bavet City, who is accused of shooting diree female garment fectory workers during a protest

outside a sport shoe factory in Bavet City last year.

But human rights groups criticized theAppeal Court's three-judge panel for sending the case right back to the Svay Rieng Provincial Court, the very court that inexplicably dropped the shooting charge against Mr. Bundith in December despite eye witness accounts identifying the governor as the sole gunman.

As with last week's hearings in the case, the Appeal Court yesterday again barred the public from the proceedings on the grounds that the hearing was merely part of an ongoing investigation and not a trial. But on leaving the courtroom, presiding Judge Khun Leang Meng paused to brief reporters on his decision to re-charge the government official.

The court, he said, "decided to charge him [Mr. Bundith] with unintentional injury and to send him to the Svay Rieng Provincial Court to be tried by the law."

Being an investigation. Judge Leang Meng said the Appeal Court had no power to issue an arrest warrant for Mr. Bundith, who has remained free ever since the February 20, 2012, triple shooting of the three young women outside a Bavet City factory making shoes for the German sports brand Puma.

Neither Mr. Bundith nor his lawyer, Mao Samvutheary, appeared in court yesterday to hear the decision. An assistant to Ms. Samvutheary attended instead, but declined to speak with reporters after the hearing.

Mr. Bundith's three alleged victims-Keo Nea, 19; Bun Chenda, 21; and Nuth Sakhom, 23-all emerged from the courtroom with smiles and welcomed the judges' decision.

" I think that he [Judge Leang Meng] has given us justice," said Ms. Nea, who was struck by a bullet in the right arm in the shooting.

" I was excited when I heard that Chhouk Bundith would still be charged," she said. " I cannot reject this decision because it is the judge's decision, even though he is [only] charged with unintentional injury."

Despite the celebratory tones expressed by the shooting victims, the decision did not sit so well with Ath Thorn, president of the Coalition of Cambodian Apparel Workers Democratic Union, who wanted to see the appeal Court bring new charges against the former city governor.

'This is still not what we want because

***Contiue Page 22***

# លោក ហ៊ុន សែន : រដ្ឋាភិបាលគ្មានលទ្ធភាព ដំឡើងប្រាក់ខែឱ្យគ្រូបង្រៀនថែមទៀតទេ

ខេមបូឌា ដេលី

លោក នាយករដ្ឋមន្ត្រីហ៊ុនសែនមានប្រសាសន៍កាលពេលថ្មីៗនេះថា រដ្ឋាភិបាលមិនមានលទ្ធភាពដំឡើងប្រាក់ខែគ្រូបង្រៀនច្រើនជាង២០ភាគរយក្នុងមួយឆ្នាំបានទេ បើមិនដូច្នេះទេគ្រូបង្រៀនរាប់ពាន់នាក់និងត្រូវកាត់បន្ថយឱ្យនៅត្រឹមចំនួនដូចគ្នានឹងគ្រូបង្រៀននៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។

ថ្លែងនៅឯពិធីប្រគល់សញ្ញាបត្រជូនគរុនិស្សិតជាង១.០០០នាក់នៅក្នុងរាជធានីភ្នំពេញ លោកនាយករដ្ឋមន្ត្រីគូសបញ្ជាក់ថា ខណៈពេលអ្នកនយោបាយប្រឆាំងបានសន្យាដំឡើងប្រាក់ខែគោលឱ្យគ្រូបង្រៀនខ្ពស់ជាងនេះ ប្រសិនបើគណបក្សរបស់ពួកគេបានឈ្នះឆ្នោតនៅខែកក្កដានោះ ការសន្យាបែបនេះ មិនអាចទៅរួចទេ សម្រាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

លោក ហ៊ុន សែន បានមានប្រសាសន៍ថា "តើយើងត្រូវការកាត់បន្ថយចំនួនគ្រូបង្រៀនឱ្យនៅត្រឹមតែ៤០.០០០នាក់ ដើម្បីបង្រៀនសិស្សចំនួន១លាននាក់...នៅពេលនោះ ប្រាក់ខែរបស់គ្រូបង្រៀន នឹងអាចដំឡើងបាន" ។ លោក ហ៊ុន សែន បានថ្លែងយ៉ាងដូច្នេះដោយសំដៅចំពោះគ្រូបង្រៀនក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និងដើម្បីទសវត្សរ៍ឆ្នាំ១៩៧០ដែលនៅពេលនោះ ប្រទេសកម្ពុជាមានគ្រូបង្រៀនចំនួន៤០.០០០នាក់សម្រាប់គ្រូបង្រៀនសិស្ស១លាននាក់ ហើយផ្ទុយគ្នានឹងពេលបច្ចុប្បន្ននេះ ដែលមានគ្រូបង្រៀន១៤០.០០០នាក់សម្រាប់បង្រៀនសិស្សចំនួន៣.៥លាននាក់។

លោកបានថ្លែងថា "ខ្ញុំសង្ឃឹមថា គ្រូបង្រៀននឹងមន្ត្រីរាជការស៊ីវិល ព្រមទាំងកងកម្លាំងប្រដាប់អាវុធទាំងអស់យោគយល់ចំពោះការដំឡើងប្រាក់ខែចំនួន២០ភាគរយជារៀងរាល់ឆ្នាំនេះ ព្រោះយើងប្រឹងខ្លាំងណាស់" ។

កាលពីសប្តាហ៍មុនគណបក្សសង្គ្រោះជាតិបានស្នើសេចក្តីព្រាងច្បាប់ថ្មីមួយនៅរដ្ឋសភាឱ្យពិចារណាដំឡើងប្រាក់ខែគោលដល់មន្ត្រីរាជការឱ្យបាន២៥០ដុល្លារក្នុង១ខែ។

ប៉ុន្តែកាលពីម្សិលមិញលោក ហ៊ុន សែន បាន

**តទៅទំព័រទី១១**

# Hun Sen Says Teacher Pay Raises Unfeasible

*By Neou Vannarin*

*THE CAMBODIA DAILY*

The government cannot afford to raise teachers´ salaries more than the 20 percent, Prime Minister Hun Sen said yesterday not unless thousands of educators are laid off and the total number of teachers is reduced to the same level as in the 1970s.

Speaking at the gradutation ce remony for more than 1,000 teachers in Phnom Penh, Mr. Hun Sen emphasized that, while opposition politicians have promised teachers a higher minimum wage if elected in July, such promise were unfeasi ble in today´s Cambodia, he said.

"Shall we reduce [the number of] teachers to only 40,000 [to teach]1 million students...[then] the teachers´ salaries will be increased," Mr. Hun Sen said, harking back staffing levels in the 1960s and early 1970s when 40, 000 teachers taught 1 million students, as opposed to 3.5 million students and 140,000 teachers today.

"I hope that teachers, govern ment officials and armed forces understand that the 20 percent increase is our best effort already," Mr. Hun Sen added.

Last week, the opposition Cam bodian National Rescue Party (CNRP) submitted a new law to the National Assembly for considera tion that would institute a minimum monthly wage of $250 for civil servants.

But Mr. Hun Sen yesterday dis missed the CNRP´s initiative as mere election-eering ahead of the July polls.

"They promise to reduce taxes and increase the civil servants [pay], but where do they get the money from?" Mr. Hun Sen asked.

The CNRP has suggested the funding for increased salaries could come from taxes on casinos and economic land concessions.

Rong Chhun, president of the Cambodian Independent Teachers´ Association, said that even a 20 percent rise would only put salaries for primary school teachers at $60 per month and those of high school teachers at $132

"Twenty percent is not enough because the inflation rate is still high," Mr. Chhun said, adding that it was pointless to compare the teachers´ situation now to more than 40 years ago.

តមកពីទំព័រទី ៣

## ស្ថានីយ៍ឧស្សាហកម្មដែកបុរាណ...

"ប្រសិនបើគ្មានការផលិតដែក នៅតំបន់នោះតែ នោះក៏គ្មានអ្វីកាត់ថ្មធ្វើប្រាសាទដែរ!""ប្រសិនបើគ្មានការផលិតដែកនៅតំបន់នោះទេ នោះក៏គ្មានអ្វីធ្វើជាសភាវុធសម្រាប់អាណាចក្រអង្គរផងដែរ!"នោះជាប្រសាសន៍ផ្ទាល់របស់សាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន ប្រធានក្រុមស្រាវជ្រាវ ។

គួរបញ្ជាក់ផងដែរថា : ស្ថានីយ៍ឧស្សាហកម្មឡស្ងួរដែកបុរាណមានតម្លៃជាប្រតិសាស្ត្រយ៉ាងសំខាន់បំផុតដែលមិនអាចកាត់ថ្លៃបាន។ តម្លៃនោះគឺបញ្ជាក់ពីស្នាដៃបុព្វបុរសខ្មែរជំនាន់ដើមមានសមត្ថភាពបច្ចេកទេសខ្ពស់ខាងវិទ្យាសាស្ត្រដែលអាចចំរ៉ាញ់ និងចេះផលិតដែកយ៉ាងស្ទាត់ជំនាញហើយយ៉ាងល្បីល្បាញនៅអាស៊ីអាគ្នេយ៍ នាំឱ្យខ្មែរ សម័យបុរាណឈានដល់អាណាចក្រអង្គររុងរឿង ។ សមត្ថភាពផលិតដែកនោះ គឺបុព្វការីជនយើងចេះផលិតនិងចំរ៉ាញដែកពីធម្មជាតិតាំងពីមុនសម័យអង្គរមកម្ល៉េះ ។ ការពិសោធន៍ដែលលោកសាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន បានធ្វើទៅលើសំណាក់សំណល់លោហៈធាតុដែកនោះបានបញ្ជាក់ថា"មានអាយុកាល១២០០ឆ្នាំ នៃគ្រឹស្តសរាជ"តាមរយៈត័រម៉ូលុយមីណេស៊ិនដេតទីន"Thremoluminescence dating"តែនោះគ្រាន់តែជាសំណាក់ស្ថិតនៅជម្រៅដី៣ម៉ែត្រចុះក្រោមប៉ុណ្ណោះ លោកបណ្ឌិតបានបញ្ជាក់បន្ថែមទៀតថា លោកត្រូវស្រាវជ្រាវជីកសំណល់ដែកនោះបន្តក្នុងជម្រៅប្រហែល៦ម៉ែត្រទៀតនោះ នឹងបញ្ជាក់ថាមានអាយុកាលមុនសម័យអង្គរឬចាស់ជាងនោះទៅទៀតផង ។

លោកបណ្ឌិតបានអំពាវនាវដល់ស្ថាប័ណ្ណ ពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រុមហ៊ុនដីសម្បទាន ក្រុមហ៊ុនរុករករ៉ែ និងការដ្ឋានសំណង់ធំសូមផ្តល់ព័តិមានឬរាយការណ៍ជាបន្ទាន់កាលណាប្រទះឃើញស្លាកស្នាមសំណល់ឧស្សាហកម្មដែកបុរាណ ព្រោះថា :"កាលណាបាត់បង់ភសតាងប្រវត្តិសាស្ត្រនោះ និងធ្វើឱ្យយើងបាត់អត្តសញ្ញាណជាតិ""កាលណាយើងមិនទទួលស្គាល់តម្លៃស្នាដៃបុព្វការីជនទេ នោះកូនចៅជំនាន់ក្រោយរបស់យើងក៏មិនគោរព និងមិនទទួលស្គាល់ស្នាដៃយើងដែរ"(វប្បធមិកាត្តញ្ញូ បណ្ឌិត ស៊ន សំណាង)។ គួរបញ្ជាក់ផងដែរថា ការស្រាវជ្រាវស្ថានីយ៍ឧស្សាហកម្មដែកបុរាណនៅកម្ពុជា លោកសាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន បានថ្លែងអំណរគុណចំពោះការគាំទ្រផ្ទាល់សម្តេចតេជោបណ្ឌិតសភាចា ហ៊ុន សែន និងឥស្សរៈជនជាន់ខ្ពស់ជាច្រើនរូបដែលបានសម្រួលនិងឧបត្ថម្ភការស្រាវជ្រាវនេះ រួមមាន ឧបនាយករដ្ឋមន្ត្រី សុខ អាន,ឧបនាយករដ្ឋមន្ត្រី គាត ឈន់,ជំទាវ ខ្លួត ធីតា ប្រធានរាជបណ្ឌិតសភាកម្ពុជា...ជាក់ស្តែងកាលពីថ្ងៃទី១៥ខែកុម្ភៈកន្លងទៅថ្មីៗនេះ ឯកឧត្តម គ្រី ទូច និងលោកជំទាវព្រមទាំងសហការីបានចុះពិនិត្យកិច្ចស្រាវជ្រាវនេះ និងបានកោតសរសើរលើកិច្ចការស្រាវជ្រាវដែលបណ្ឌិតសភាបានធ្វើ ។ ឯកឧត្តម គ្រី ទូច និងថ្នាក់ដឹកនាំមួយចំនួនបានសំណូមពរឱ្យរក្សាទុកទីតាំងឧស្សាហកម្មបុរាណនោះ ដោយប្រែទៅជាឧទ្យានជាតិ សម្រាប់អភិរក្សនិងជាទីរមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រវប្បធមិ និងធម្មជាតិទៅអណាគត ។ លោកបណ្ឌិត ក៏បានសំណូមពរ និងអំពាវនាវដល់ជនរួមជាតិ អ្នកស្នេហាប្រវត្តិសាស្ត្រមេត្តាជួយផ្តល់ការគាំទ្រទាំងកម្លាំងចិត្ត និងជាសម្ភារៈដល់គំរោងការស្រាវជ្រាវរបស់លោកតាមរយៈអសយដ្ឋានទំនាក់ទំនង : រាជបណ្ឌិតសភាកម្ពុជាប្រអប់សំបុត្រ ២៦១៣ ភ្នំពេញពកម្ពុជា ទូរស័ព្ទ ០១២ ៩២៦ ៣៩០ អ៊ីម៉ែល : chanthourn@yahoo.comទូរសារ: www.cambodiaresearch.com ៕






LOWELL ELDER CARE 978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ 978-596-1111 – www.lowelleldercare.com

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង៍ គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង៍ និង៍ជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និង៍ផ្នែកសង្គម ។ កម្មវិធីរបស់យើង៍ធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និង៍មានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំង៍អាចរកឃើញដោយង៉ាយក្នុង៍អគារថ្មី ជាមួយនូវការតុបតែង៍រចនាបែបសិល្បៈខ្មែរយ៉ាង៍ល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និង៍មានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និង៍កន្លែង៍ផ្សេង៍ៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។



### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និង៍ថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និង៍ក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និង៍ចំណីផ្សេង៍ៗ
- ការហាត់ប្រាណសំរាប់សុខភាពរាង៍កាយ
- កម្មវិធីសិល្បៈ និង៍តន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និង៍ការសំណេះសំណាលគ្នា)
- សកម្មភាព និង៍ដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

សូមហៅទៅលោក ខឡ រស 978 996 6127

# KR Tribunal Stopped by Strike Over Salaries

*BY LAUREN CROTHERS*

*THE CAMBODIA DAILY*

Proceedings at the Khmer Rouge war crimes tribunal were halted yesterday when Cambodian staff from the Interpretation and Translation Unit (ITU) went on strike, saying they would not return to work utilities are paid their salaries.

The strike-the first in the tribunal's history-was announced as the hearing began, when the voice of a Khmer-to-English interpreter came over the live feed and said that staff fix) from the ITU would strike with immediate effect until they are paid three months worth of over-due wages.

"Mr. President, a message from the interpreters," the speaker said in reference to Trial Chamber President Nil Nonn. "Mr. President and your honors and parties to the proceedings, we, the ITU staff of the ECCC, arenow implementing our work boycott. We won't get back to work until our salaries for December 2012 and January and February 2013 are paid.

" The Trial Chamber judges quickly convened to decide how to proceed without the help of the interpreters. After 45 minutes, the hearing resumed, but the court was informed by the ITU that it would only continue for another half hour because "after that, it is not technically feasible to continue," a French-to-English translator said, speaking on behalf of his national counterparts.

Before proceedings stopped, the judges told the court that co-accused Ieng Sary had been hospitalized that morning, and that the testimony of expert witness Philip Short, which was scheduled for yesterday, would be delayed.

National staff at the tribunal have been threatening to strike since January over a worsening financial crisis that has seen most of them

go unpaid since November. They have also been working without any employment contracts since the beginning of the year.

Speaking by telephone on condition of anonymity, and directly after ITU staff were called into a meeting with management following

the prematurely adjourned hearing, one of the national court interpreters said that 30 staff from the unit had decided they had no choice but to strike.

"Everyone shares the same concerns," the interpreter said. "We are not going back to work unless the demand in our statement is met."

He said unit staff had been "afraid" of the court's Office of Administration for "a long time," and felt that it had only offered empty promises that staff would eventually be paid if they held out and waited.

"But at this point in time, we have been very patient, very polite, and I think patience has its limits," the interpreter said. "We can't keep working without pay for three months in a row without employment contracts; I can't find any reason why staff would work."

The interpreter added that the Office of Administration, which is headed by acting director Tony Kranh, "is doing its best to make sure we can be suppressed, intimidated and cajoled to calm down and stay as calm as possible over the next few weeks or months." Yesterday's meeting was the first time Mr. Kranh personally met with the unit staff, the interpreter said.

After being asked to return to work in the morning meeting, the unit staff again met with a representative from the office in the afternoon

and staff were told their boycott had been carried out without proper grounds and warning to judges. They were also told that they would not be paid unless they returned to work, and that the U.N. was looking to find replacements

for them, the interpreter said.

Mr. Kranh hung up twice on a reporter yesterday.

The interpreter also called on the government to "stop interfering in court affairs" and suggested political interference in the case was the reason national staff are going unpaid.

Court monitors have said that long-standing allegations of political interference give rise to reticence among donors.

While other media reports yesterday inferred that the onus is on donor countries to solve the salary crisis. Article 15 of the ECCC agreement between the U.N. and the government actually states that "salaries and emoluments of Cambodian judges and other

Cambodian personnel shall be defrayed by the Royal Government of Cambodia"

In principle, the government and U.N. are supposed to take care of national and international salaries, respectively. In practice, salaries on both the national and international sides are largely funded by donors.

The government pledge of $1.8 million toward the court's 2013 budget, however, has done little to contribute meaningfully to the payment of salaries, and a failure to pay the staff effectively means that the government is in breach of the agreement.

Reached by telephone yesterday, Ek Tha spokesman for the Office of the Council of Ministers, said the government did not have the means to contribute any more, and called on donor countries to step in and pledge money.

"The government has no budget available to contribute to the ECCC," he said, "because the government contribution for the ECCC already exceeds the commitment from the national budget to the country's Supreme Court by 2,'57 percent and to the ***Contiue to Page 12***




តមកពីទំព័រទី ០៩ 

## លោក ហ៊ុន សែន៖ រដ្ឋាភិបាលគ្មានលទ្ធភាព...

ច្រានចោលនូវគំនិតផ្តួចផ្តើមរបស់គណបក្សសង្គ្រោះជាតិក្នុងការដំឡើងប្រាក់ខែមន្ត្រីរាជការនេះ ដោយលើកឡើងថា នេះគ្រាន់តែជាល្បិចកល ដើម្បីទទួលបានសំឡេងឆ្នោតនៅក្នុងការបោះឆ្នោតនៅខែកក្កដាតែប៉ុណ្ណោះ។

លោក ហ៊ុន សែន បានសួរថា "ពួកគេសន្យាកាត់បន្ថយពន្ធ ហើយដំឡើងប្រាក់ខែឱ្យបុគ្គលិកមន្ត្រីរាជការ ស៊ីវិល ប៉ុន្តែតើពួកគេបានលុយមកពីណា?"។

គណបក្សសង្គ្រោះជាតិបានស្នើឱ្យមានថវិកាសម្រាប់ដំឡើងប្រាក់ខែឱ្យមន្ត្រីរាជការ ស៊ីវិល ដោយយកថវិកាបានមកពីការយកពន្ធ លើកាស៊ីណូ ពន្ធដីសម្បទានសេដ្ឋកិច្ច និងការបង្វែរប្រាក់ពុករលួយចូលក្នុងថវិកាជាតិវិញ។

លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជា ឯករាជ្យមានប្រសាសន៍ថា ទោះបីរដ្ឋាភិបាលបានដំឡើង២០ភាគរយក៏ដោយ ក៏ប្រាក់ខែសម្រាប់គ្រូបង្រៀននៅថ្នាក់បឋមសិក្សាមានត្រឹមតែ៦០ដុល្លារប៉ុណ្ណោះ ក្នុងមួយខែ និងប្រាក់ខែសម្រាប់គ្រូបង្រៀននៅថ្នាក់មធ្យមសិក្សាទទួលបានតែ១៣២ដុល្លារក្នុងមួយខែ។

លោក រ៉ុង ឈុន មានប្រសាសន៍ថា "ការដំឡើងប្រាក់ខែ២០ភាគរយ គឺមិនទាន់គ្រប់គ្រាន់ទេ ដោយសារអតិផរណាខ្ពស់ពេក។ យើងទាមទារឱ្យមានការដំឡើងប្រាក់ខែគោលសម្រាប់គ្រូបង្រៀននិងមន្ត្រីរាជការ ស៊ីវិល "អប្បបរមា"ចំនួន២០០ដុល្លារ ដើម្បីឆ្លើយតបតាមកម្រិតអតិផរណានាពេលបច្ចុប្បន្ននេះ"។

លោក រ៉ុង ឈុន ក៏បានមានប្រសាសន៍ថា វាមិនសមហេតុផលទាល់តែសោះដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រៀបធៀបអំពីស្ថានភាពរបស់គ្រូបង្រៀនក្នុងពេលបច្ចុប្បន្ននេះទៅនឹងស្ថានភាពរបស់គ្រូបង្រៀនកាលពីជាង៤០ឆ្នាំកន្លងមក ហើយនោះដោយលោកបានលើកឡើងថា ការកាត់បន្ថយគ្រូបង្រៀននៅក្នុងប្រទេសគឺជាការដើរថយក្រោយ៕

Contiue From Page 11
## KR Tribunal Stopped by Strike Over...

Appeals Court by 300 percent"

"In terms of the ECCC, the international side cannot work without the national side," he said. "In other words, a bird cannot fly with one wing."

Mr. Tha appealed to donor countries to meet the shortfall.

According to its revised budget for the year, the national component needs $9.4 million to fulfill its operational obligations.

Court press officer Neth Pheaktra said he had no prior knowledge of the ITU intentions, and was "surprised" when they announced the strike.

In an email, Mr. Pheaktra said: "Other national staff that are facing the same problems as their colleagues at the ITU will also boycott their work if they still do not get paid, because they cannot survive. All staff play a crucial role to maintain the good function of ECCC."

Yesterday was the day Mr. Short, expert witness and author of 'Pol Pot Anatomy of a Nightmare," was supposed to give testimony.

With no end in sight to the strike and Ieng Sary in Khmer-Soviet Friendship Hospital, it is unclear if or when Mr. Short will be heard in court.

Ieng Sary's international defense lawyer Michael Karnavas said outside court yesterday that he learned at 7:10 am. that his client was being taken to the emergency ward.

"We understand he had excessive diarrhea and was vomiting," Mr. Karnavas said, adding that " it would be fanciful to say that for someone like Short that Ieng Sary would waive his right to be present"

He also said that while this strike is "regrettable, it is understandable."

"Behind every face, there's a family that relies on this," he added.

Ky Bousuor, a doctor at Khmer-Soviet Friendship Hospital, said Ieng Sary arrived at 7:30 am.

"He had a stomach ache and heartburn," Dr. Bousuor said. "We don't know how long he will stay in hospital; it depends on the situation of his illness."

After the announcement of the strike and halt in proceedings, some 500 people who were visiting the court from Kompong Speu and Takeo provinces went home largely disappointed.

Thap Bun Theang, 58, who traveled from Banteay Meanchey province in the hope of attending an afternoon session, voiced his unhappiness at being unable to witness proceedings.

"I want to see how the court proceeds, whether it's fair or not," he said.

Panhavuth Long, a program officer for the Cambodian Justice Initiative, said it was becoming ever clearer that funding and health problems are two of the court's biggest battles.

"Funding is a big issue and health issues are continuing to be an alarming issue that may interrupt the proceedings of the ECCC," he said.

"I think it's very important that staff get paid.... This is a test of whether the Cambodian government is committed to the rule of law and ending impunity and providing more support so they could involve the proceedings to go ahead."

(Addition reporting by Khy Sovuthy and Chin Chan)

តមកទំព័រទី ៥
## អ្នកក្រ និងអ្នកមាន....

និងសួនកម្សាន្តវិញ ដើម្បីទាក់ទាញទេសចរយកលុយទៅចាយដែលជាសកម្មភាពសេដ្ឋកិច្ចផ្ទាល់។ ចំពោះភ្នំពេញវិញ ចាប់ពីវាំងទៅជើងតាមវិថីស៊ីសូវ៉ាត់ គួរតែសុទ្ធតែសណ្ឋាគារ ភោជនីយដ្ឋាន ក្លិបកាហ្វេ សួនច្បារតូប(KIOSK)លក់ដូរស៊ូវើនៀរ(SOUVENIR)និងរបស់ហូបចុកថោកល្មមសម្រាប់អ្នកធម្មតាមិនសូវមានលុយច្រើនចូលហាងធំៗ។ ហើយនៅពេលយប់ចាប់ពីម៉ោង៥ល្ងាចដល់២ព្រឹកមិនត្រូវមានចរាចរម៉ូតូនិងឡានតាមកំណាត់ផ្លូវ នោះដាច់ខាតវៀសតែឡានដឹក ភ្ញៀវចេញចូលសណ្ឋាគារឡានទឹកនិងឡានពេទ្យនៅពេលមានអាសន្ន។ ទាំងអស់ត្រូវដើរវេលានោះ។

ជាគន្លឹះ រដ្ឋាភិបាលត្រូវរកមធ្យោបាយធ្វើ យ៉ាងម៉េចឱ្យបានកន្លែងនីមួយៗដំឡៃថោក ដើម្បីឱ្យបានចំណូលនិងចំណេញច្រើន ម្យ៉ាងទៀតធ្វើយ៉ាងម៉េចណែនាំឱ្យមនុស្សកាន់តែច្រើនឡើង ច្រើនឡើងចាប់មុខរបរធ្វើជំនួញ។

ហើយត្រូវរិះរកមធ្យោបាយយ៉ាងម៉េចធ្វើឱ្យមនុស្សច្រើនឡើងសប្បាយមានការធ្វើរកស៊ីចំណេញ មានឡើងៗ។ មនុស្សតែងតែចាយលុយកាលណាសប្បាយចិត្ត។

ថ្ងៃក្រោយ នឹងនិយាយអំពីថា តើរដ្ឋាភិបាល ជួយអ្នកជំនួញតាមផ្លូវច្បាប់យ៉ាងម៉េច ដើម្បីឱ្យអ្នកជំនួញសម្រេចគោលដៅបាន។

Mr. Sos Kem

Retired Foreign Service Officer

U.S. Department of State

soskem@yahoo.com






# មណ្ឌលគិរីជាតំបន់ស្រូបយកភ្ញៀវទេសចរ





មណ្ឌលគិរីជាតំបន់ស្រូបយកភ្ញៀវទេសចរបរទេសអេកូទេសចរណ៍ខេត្តមណ្ឌលគិរីនៅមានវិសាលភាពធំធេងដែលអាចទាក់ទាញភ្ញៀវអន្តរជាតិបានច្រើន ។ ដោយឡែកភ្ញៀវអឺរ៉ុបបើបានមកដល់តំបន់អេកូទេសចរណ៍ខេត្តនេះ ប្រាកដជាជក់ចិត្តជិតអារម្មណ៍ទៅនឹងសម្រស់ធម្មជាតិមួយកម្របានជួបប្រទះ ។ ថ្មីៗកន្លងទៅនេះ ទេសចរជនជាតិអង់គ្លេស២នាក់ បានទៅដល់ខេត្តមណ្ឌលគិរីតាមរយៈក្រុមហ៊ុនទេសចរណ៍មួយដែលមានឈ្មោះហៅថា សែនមនោរម្យតួរី ។ ភ្ញៀវទាំង២នាក់នេះ ស្នាក់នៅទីនោះជាច្រើនថ្ងៃដោយគាត់បានទស្សនាឃើញផលិតផលទេសចរណ៍ថ្មីនៅក្នុងខេត្តនេះ ។ លោក ម៉ាទីន ហ្គោដ (Martin Good) ទេសចរវ័យចំណាស់ជនជាតិអង់គ្លេស២នាក់ប្តីប្រពន្ធបានចាប់អារម្មណ៍ថា គាត់ចង់រស់នៅកម្សាន្តសប្បាយទីនេះយូរថ្ងៃ ។ គាត់បានជិះដំរីទស្សនាចម្ការម្រេចទស្សនាចម្ការកាហ្វេទស្សនាសហគមន៍ជនជាតិភាគតិចទៅលេងទឹកជ្រោះក្បាលព្រះ ។ គាត់ស្នាក់នៅបរិភោគអាហារប្រកបដោយសេវាបម្រើល្អគួរឱ្យកោតសរសើរ ។ ក្នុងវ័យ៧៥ឆ្នាំរបស់លោកៗមិនដែលបានឃើញទឹកដីព្រៃភ្នំវាលស្មៅជិះដំរីសប្បាយដូចថ្ងៃនេះទេ ។ លោកបានស្វែងយល់ពីជីវភាពរស់នៅរបស់ជនជាតិភាគតិចដ៏កម្រ ។ ទេសចរជនជាតិអង់គ្លេសរូបនេះបានសន្យាថា ទៅកាន់ប្រទេសគាត់វិញនឹងនាំយកក្តីសប្បាយរីករាយពីតំបន់អេកូខេត្តនេះទៅផ្សព្វផ្សាយឱ្យប្រជាជនគាត់បានដឹង និងនាំគ្នាមកលេងតំបន់នេះឱ្យបានច្រើនទៀត ។ លោក ម៉ី កុសល នាយកចាត់ចែងគ្រប់គ្រងសែនមនោរម្យតួរីបានលើកឡើងថា ខេត្តមណ្ឌលគិរីមកដល់ពេលនេះនៅមិនទាន់មានអ្វីធ្វើឱ្យខូចខាតអេកូធម្មជាតិអ្វីធំដុំដូចខេត្តខ្លះនៅភូមិភាគឦសាននោះទេ ។ អេកូធម្មជាតិនៅតែជាចំណីភ្នែកទេសចរគួរឱ្យទាក់ទាញចង់ទៅទស្សនា ។ ខេត្តនេះនៅមានផលិតផលទេសចរណ៍ថ្មីជាច្រើនកន្លែងទៀតសម្រាប់ឱ្យភ្ញៀវទស្សនាក្រៅពីទឹកជ្រោះប៊ូស្រា និងវាលស្មៅនៅស្រុកវាលវែង ។ មានសេវាឯកជនរកស៊ីដឹកជញ្ជូនភ្ញៀវទេសចរមួយចំនួនបាននាំភ្ញៀវទៅទស្សនាខេត្តនេះ គឺគ្រាន់តែទស្សនាកន្លែងរមណីយដ្ឋានដដែលៗ ដោយមិនចេះរកឃើញនូវផលិតផលទេសចរណ៍ថ្មីៗឡើយ ។ តាមពិតខេត្តនេះមានកន្លែងលេងកម្សាន្តជាច្រើនដែលសេវាកម្មដឹកជញ្ជូនអត់បានស្គាល់ ៕









## តមកពីទំព័រទី ៦ សំណុំរឿង ឈូក បណ្ឌិត ត្រូវបង្វែរទៅ...

បានមានប្រសាសន៍ថា សាលាឧទ្ធរណ៍មិនមានសិទ្ធិចេញដីការចាប់ខ្លួនលោក ឈូក បណ្ឌិត ដែលនៅមានសេរីភាពជាធម្មតាចាប់តាំងពីការបាញ់ប្រហារកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ទៅលើកម្មការិនីកាត់ដេរចំនួន៣នាក់ នៅខាងក្រៅរោងចក្រស្បែកជើងម៉ាកពូម៉ា (Puma) ឱ្យក្រុមហ៊ុនលក់ស្បែកជើងកីឡារបស់ប្រទេសអាល្លឺម៉ង់នោះទេ ។

ទាំងលោក ឈូក បណ្ឌិត និងមេធាវីរបស់គាត់គឺលោក ស្រីម៉ៅ សំវុទ្ធារី មិនបានបង្ហាញខ្លួននៅតុលាការ ដើម្បីស្តាប់ការម្រេចរបស់តុលាការទេ កាលពីម្សិលមិញ ។ តែជំនួយការរបស់លោកស្រី សំវុទ្ធារី បែរជាមកចូលរួមជំនួសវិញ ប៉ុន្តែបានបដិសេធមិននិយាយជាមួយអ្នកយកព័ត៌មានឡើយ បន្ទាប់ពីការបើកសវនាការនេះ ។

ជនរងគ្រោះទាំងបីដែលបានចោទប្រកាន់លោក ឈូក បណ្ឌិត មានឈ្មោះ កែវ នា អាយុ ១៩ឆ្នាំ ប៊ុន ចិន្តា អាយុ២១ ឆ្នាំ និង នុតសាខន អាយុ២៣ឆ្នាំ សុទ្ធតែចេញពីបន្ទប់សវនាការមកវិញទាំងញញឹម ហើយបានស្វាគមន៍ចំពោះការសម្រេចរបស់ចៅក្រម ។

ជនរងគ្រោះឈ្មោះ កែវ នា ដែលត្រូវគ្រាប់កាំភ្លើងចំដៃស្តាំ អំឡុងពេលបាញ់នោះ និយាយថា "ខ្ញុំគិតថា លោកចៅក្រម លាង ម៉េង បានរកយុត្តិធម៌ឱ្យយើងហើយ" ។

ជនរងគ្រោះរូបនោះ បាននិយាយបន្តថា "ខ្ញុំរំភើបណាស់ នៅពេលខ្ញុំបានឮថា លោក ឈូក បណ្ឌិត នៅតែទទួលរងការចោទប្រកាន់ ។ ខ្ញុំមិនអាចច្រានចោលសេចក្តីសម្រេចនេះបានទេ ពីព្រោះនេះជាការសម្រេចរបស់ចៅក្រម ទោះបីជាលោក ឈូក បណ្ឌិត គ្រាន់តែរងការចោទប្រកាន់ពីបទបង្ករបួស្នាមដោយអចេតនាក៏ដោយ "។

ទោះបីមានការលើកឡើងទាំងសប្បាយចិត្តជនរងគ្រោះពីការបាញ់ប្រហារទាំងនេះក្តីក៏ការសម្រេចនេះមិនបានធ្វើឱ្យលោក អាត់ ធន់ ប្រធានសហព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដែលចង់ឃើញសាលាឧទ្ធរណ៍ដាក់ការចោទប្រកាន់ថ្មីចំពោះលោក ឈូក បណ្ឌិត ចេញចិត្តឡើយ ។

លោកមានប្រសាសន៍ថា "នេះមិនមែនជាអ្វី ដែលយើងចង់បានទេ ពីព្រោះករណីនេះ បានបង្កឱ្យមានការខូចខាតច្រើនណាស់ ហេតុដូច្នេះហើយបទចោទប្រកាន់នេះគួរតែជាអំពើមនុស្សឃាតដោយចេតនា" ។

អង្គការសិទ្ធិមនុស្សអាដហុក និងគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា ជាអង្គការចម្រុះមាន២០អង្គការបានរិះគន់ចៅក្រមចំពោះការបញ្ជូនសំណុំរឿងនេះត្រឡប់ទៅកាន់សាលាដំបូងខេត្តស្វាយរៀងវិញ ជាតុលាការដែលបានលើកលែងការចោទប្រកាន់ចំពោះលោក ឈូក បណ្ឌិត កាលពីខែធ្នូ ។

លោក ឈូក បណ្ឌិត នៅតែបំរើការជាមន្ត្រីរដ្ឋាភិបាលក្នុងខេត្តស្វាយរៀងដដែល ។

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា និងអង្គការសិទ្ធិមនុស្សអាដហុក បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍រួមមួយថា "យើងព្រួយបារម្ភថា ការស៊ើបអង្កេតលើសំណុំរឿងនេះ ស្ថិតក្រោមយុត្តាធិការរបស់សាលាដំបូងខេត្តស្វាយរៀងដែលធ្លាប់បង្ហាញឱ្យឃើញពីមុនម្តងហើយថា តុលាការនេះប្រហែលជាទទួលរងសម្ពាធនយោបាយពីលោក ឈូក បណ្ឌិត និងអ្នកគាំទ្ររបស់គាត់" ។

សេចក្តីថ្លែងការណ៍នេះ ក៏បានអំពាវនាវឱ្យសាលាដំបូងខេត្តស្វាយរៀងធានាឱ្យបានដែរថា ការស៊ើបអង្កេតឡើងវិញលើសំណុំរឿងរបស់លោក ឈូក បណ្ឌិត ត្រូវតែធ្វើឡើងឱ្យបានត្រឹមត្រូវបំផុត ។

សេចក្តីថ្លែងការណ៍នេះបានបន្តថា "ការស៊ើបអង្កេតឱ្យបានហ្មត់ចត់នៅក្នុងសំណុំរឿងបាញ់ប្រហារនេះ មិនមែនគ្រាន់តែដើម្បីរកយុត្តិធម៌ឱ្យជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីបង្ហាញពីភាពឯករាជនៃប្រព័ន្ធតុលាការកម្ពុជាផងដែរ" ។

នៅពេលសកម្មជនការពារសិទ្ធិមនុស្សបានលើកឡើងកាលពីម្សិលមិញ ខ្លួនសង្ឃឹមថា ការសម្រេចរបស់សាលាឧទ្ធរណ៍ និងធ្វើឱ្យមានការស៊ើបអង្កេតពេញលេញលើសំណុំរឿងនេះលោកចៅក្រម លាងម៉េង បានមានប្រសាសន៍ថា បញ្ហានេះមិនស្ថិតនៅក្នុងរបៀបវារៈឡើយ ។

លោកបានមានប្រសាសន៍ដោយមិនប្រាប់ហេតុផលថា "យើងបានបញ្ជូនសំណុំរឿងនេះ ទៅឱ្យសាលាដំបូងខេត្តស្វាយរៀងបើកសវនាការតែម្តង យើងមិនមែនបញ្ជូនឱ្យស៊ើបអង្កេតឡើងវិញឡើយ" ។

លោញ ប៊ុច ឈឿត ប្រធានសាលាដំបូងខេត្តស្វាយរៀង បានមានប្រសាសន៍ថា គ្មានការស៊ើបអង្កេតឡើងវិញលើសំណុំរឿងលោក ឈូក បណ្ឌិត ឡើយ ។

លោកថ្លែងថា "យោងតាមច្បាប់យើងមិនមានសិទ្ធិស៊ើបអង្កេតសំណុំរឿងនេះឡើងវិញទេ ។ យើងនឹងបញ្ជូនសំណុំរឿងនេះទៅបើកសវនាការដោយផ្ទាល់តែម្តង" ។

អំឡុងពេលបើកសវនាការនៅសាលាឧទ្ធរណ៍កាលពីសប្តាហ៍មុនលោក ឈូក បណ្ឌិត បានទទួលស្គាល់ចំពោះមុខតុលាការថា លោកពិតបានដកកាំភ្លើងខ្លីបាញ់ឡើងទៅលើមេឃអំឡុងការតវ៉ានោះ ប៉ុន្តែលោកបានអះអាងថា លោកមិនដឹងថា គ្រាប់កាំភ្លើងទាំងនោះទៅទិណានោះទេ ។

មន្ត្រីនគរបាលជាង២០នាក់ដែលបានបំពេញតួនាទីរបស់ខ្លួន អំឡុងការតវ៉ានៅរោងចក្រផលិតស្បែកជើងនោះ និងអំឡុងពេលមានការបាញ់ទៅលើកម្មការិនីទាំងបីនាក់បានប្រាប់សាលាឧទ្ធរណ៍ថា ពួកគេបានឮសូរកាំភ្លើង ប៉ុន្តែមិនបានឃើញអ្នកបាញ់កម្មការិនីទាំងនេះទេ ។

ទោះជាយ៉ាងណាមន្ត្រីនគរបាលម្នាក់ គឺលោក ឡុង ភន នាយរងប៉ុស្តិ៍សង្កាត់ប្រាសាទក្រុងបាវិត បានផ្តល់សក្ខីកម្មកាលពីសប្តាហ៍មុនថា លោកបានឃើញលោក ឈូក បណ្ឌិត ដកកាំភ្លើងខ្លីរបស់ខ្លួនបាញ់ទៅលើកម្មករកម្មការនីរោងចក្រកាត់ដេរដែលកំពុងតវ៉ាដោយធ្វើឱ្យមនុស្សយ៉ាងហោចណាស់ម្នាក់រងរបួស ។

កាលពីថ្ងៃសុក្រលោក ឡុង ភន លើកឡើងថា ក្រោយមកថ្នាក់លើរបស់លោកម្នាក់បានទូរស័ព្ទទៅរិះគន់សក្ខីកម្មរបស់លោកហើយលោកមានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ ខ្លួននិងសុវត្ថិភាពរបស់គ្រួសារលោក ។

កាលពីថ្ងៃអាទិត្យមន្ត្រីនគរបាលក្រុងបាវិតរូបនេះ បានដកពាក្យសម្តីដែលអះអាងថា ថ្នាក់លើរបស់លោកបានគំរាមកំហែងលោកវិញ ដោយមិនពន្យល់ហេតុផលអ្វីឡើយ ប៉ុន្តែប្រពន្ធរបស់គាត់នៅតែសម្តែងការភ័យខ្លាចចំពោះការសងសឹកដោយសារការផ្តល់សក្ខីកម្មរបស់ប្តីគាត់នៅក្នុងតុលាការ ៕ *ប្រែសម្រួលដោយ ស៊ា ស៊ុយឈាង*



តមកពីទំព័រទី ០៧

## រដ្ឋកាលបន្ទាប់ពីសីហនុ...

ដើម្បីរក្សាព្រះរាជបល្ល័ង្ករបស់ព្រះអង្គ ។ នេះជាមរតដ៏យ៉ាប់យឺនសម្រាប់ស្តេចអង្គថ្មី បន្តអំណាចតស៊ូចេញពីភាពរណបមកឯករាជ្យជូនរាស្ត្រយ៉ាងអស់សង្ឃឹម ។ រាស្ត្រខ្មែរនៅតែមិនជឿថា ខ្លួនអាចរស់នៅដោយគ្មានស្តេចបាននៅឡើយ តែពួកគាត់ត្រូវការស្តេចក្លាហានលះបង់ដើម្បីរាស្ត្រ ដើម្បីប្រទេសជាតិដែលទស្សនៈជាតិនេះមិនខុសគ្នាពីបក្សព្រឆាំងសព្វថ្ងៃនេះទេ គួរតែរួមកម្លាំងគ្នាបាន ។

**ហេតុដែលពុំកម្លាំងរួបរួមមិនបាន :**

• **ការមិនចាំមេរៀននៃអតីតកាលៈ** មានការជឿលើមនុស្សបណ្តោះអាសន្ន ពុំមានការប្តេជ្ញាចិត្តធ្វើតែអំពើល្អ ការបង្ហាញពីភាពស្នេហាជាតិ គ្រប់ពេលនឹងគ្រប់សកម្មភាព ការមិនរៀនពីប្រវត្តិសាស្ត្រជាតិឯង ស្វែងយល់ពីវិបត្ត និងបុព្វហេតុនៃការចុះខ្សោយពីអតីតកាល គ្មានគោលការណ៍សំរាប់ជីវិតដឹកនាំសកម្មភាពខ្លួននឹងគ្រួសារ ឱ្យចាប់អារម្មណ៍ពីព្រឹត្តិការណ៍ជាតិរបស់ខ្លួន **<u>ឧទាហរណ៍:</u>** គេមិនអាចបំភ្លេចបានថាខ្មែរក្រហមមានសារជាតិកុម្មុយនិស្ត បានធ្វើឱ្យខ្មែរបាត់បង់ជីវិតច្រើនលាន់នាក់ក្នុងទារុណកម្ម ហើយចុងបញ្ចប់ធ្វើឱ្យបាត់បង់ទឹកដីនិងអធិបតេយ្យជាតិថែមទៀត ដូច្នេះពុំអាចទៅជាគំរូ ឬវីរៈភាពក្នុងរូបភាពណាមួយរាប់ទាំងមនុស្សដែលធ្លាប់គាំទ្រពួកខ្មែរក្រហមកាលពីអតីតកាលផង សំរាប់មនុស្សជំនាន់ក្រោយទេ ។

• **ការមិនស្គាល់ពីខ្មាំងរបស់ជាតិឯង :** ខ្មាំងរបស់ជាតិខ្មែរ មិនចាំបាច់តែអ្នកនោះជាបរទេសនោះទេ សូម្បីតែខ្មែរ ដូចគ្នាក៏អាចជាខ្មាំងបាន



ដែរ ហើយមិនសំគាល់មិត្តរបស់ខ្មែរ ដោយសារសញ្ញាប័ត្រធំខ្ពស់ ឬមានសម្បត្តិស្តុកស្តម្ភ ឬមានឋានៈខ្ពង់ខ្ពស់ ថាជាវណ្ណៈដឹកនាំគេនោះទេ ខ្មាំងនៃការរួបរួមខ្មែរ គឺការភូតភរការយកទ្រព្យអ្នកដ៏ទៃជាសម្បត្តិខ្លួនឯង ដោយគ្មានការយល់ព្រមពីម្ចាស់ទ្រព្យការក្លែងបន្លំការមិនជួយយកអាសារជនជាតិឯងឱ្យបានយ៉ាងហោចណាស់ស្មើប្រយោជន៍នៃជនសាសន៍ដ៏ទៃ ហើយលក្ខណៈនៃការខ្វះសីលធម៌នេះ សូម្បីតែខ្លួនឯងផ្ទាល់ក៏ជាក្លាយទៅជាសត្រូវនៃការរួបរួមជាតិបានដែរ។ ដូច្នេះគឺការស្គាល់ពីខ្លួនឯងចង់បានអ្វី ? ស្គាល់ពីអ្នកដ៏ទៃដែលអាចរាប់មិត្តបាន ? ស្គាល់ពីសុខទុក្ខសហគមន៍ខ្លួនឯងថា ត្រូវការអ្វី ? ហើយនាំគ្នាស្វែងរកសីលធម៌ដែលជាគំរូជាមូលដ្ឋាននៃការរួបរួមបង្កើនកម្លាំងជាតិរៀងៗខ្លួនទើបរស់នៅជាមួយគ្នាបាន។ អ.ស.ប បានបន្សល់ឱ្យកម្ពុជាបង្កើតស្ថាប័នជាច្រើនសំរាប់ការពារសីលធម៌ជាមូលដ្ឋាននៃការរួបរួមគ្នា តែក៏នៅទែមានមនុស្សជាច្រើនមិនជឿមិនស្គាល់ ហើយមិនចូលរួមនៅឡើយ ។

• **ការខ្វះការអប់រំៈ** មនុស្សត្រូវទទួលការអប់រំ រៀនសូត្រជាប្រចាំ ដើម្បីឱ្យស្គាល់ ហើយស្រឡាញ់អ្នកស្នេហាជាតិខ្លួនឯង។ គ្មានការអប់រំគឺបង្កើតភាពងងឹត ការខ្លាចនឹងការចូលរួមជ្រើសយកតែភាពងាយស្រួលសំរាប់ដំណើរនៃជីវិត។ ភាព "ឈិនឆៃ"លើការស្គាល់ និងស្រឡាញ់សីលធម៌របស់សហគមន៍ខ្មែរបានទុកឱកាសឱ្យសត្រូវនៃការរួបរួមបំផ្លាញបានយ៉ាងងាយស្រួល។ កាសែតទូរទស្សន៍ជាច្រើនបានលើកយកសីលធម៌នៃវិជ្ជាជីវរបស់ខ្លួនមកអប់រំមនុស្សឱ្យក្លាយជាអ្នកចេះអ្នកពិចារណាត្រឹមត្រូវដោយមិនចាំបាច់ឱ្យមនុស្សទៅរៀននៅសាលាឯណាឆ្ងាយតែមនុស្សខ្មែរនៅតែចូលចិត្តការអប់រំដែលភ្លើតភ្លើនស្រឡាញ់លុយជាងចំណេះស្រឡាញ់បុណ្យស័ក្តិជាងសីលធម៌ធ្វើខ្លួនឯងវង្វេងផ្លូវពុំដឹងជាតើត្រូវដើរទៅទិសណា? ភាពមិនច្បាស់លាស់ និងជម្ងឺខ្លាច ក៏បានកើតឡើង។ បន្ថែមពីលើការអប់រំសីលធម៌បច្ចេកវិជ្ជាថ្មីទំនើបក៏ត្រូវតែរៀនប្រើសំរាប់ការរស់នៅសម័យថ្មីក្នុងនោះគេបានបញ្ចូលវិន័យជាសីលធម៌សម័យមួយចំនួនដែលបានជួយបង្កើតសង្គមយុវវ័យដែលបន្តដំណើររួបរួមគ្នារកភាពរីកចម្រើនក្នុងលីសធម៌បានទាំងនេះពន្លឺរំងាប់ការខ្លាច **"ខ្មោចលង"** ឱ្យដើរផ្លូវឆ្ងាយបាន។

ជារួមស្ថានភាពខ្មែររួបរួមគ្នានៅក្រៅស្រុកមានសភាពប្រសើរជាងក្នុងស្រុកច្រើន ដោយសារបរិដ្ឋានរស់នៅមានភាពបរិសុទ្ធច្រើនជាងនៅកម្ពុជា ប៉ុន្តែក៏នៅតែខ្វះការស្វែងរកអ្នកស្រឡាញ់សីលធម៌សំរាប់រួបរួមគ្នានៅឡើយ។ ស្ថានភាព "ភ្នំភ្លើងត្រៀមផ្ទុះ"នៅកម្ពុជា មិនច្បាស់សំរាប់រំលាយប្រទេសជាតិតែមួយមុខទេ វាក៏អាចជួយជាតិឱ្យផ្លាស់ប្តូរការគ្រប់គ្រង ហើយមនុស្សបរិសុទ្ធអាចរួបរួមគ្នាបង្កើតបរិដ្ឋានបរិសុទ្ធថ្មីបានដែរ។ សម្តេចនរោត្តម សីហនុ បានយាងចាកលោកនេះទៅបានទុកឱ្យអារម្មណ៍ម្នាក់ទំនេរពីការគិតពីអំណាចឥទ្ធិពលនៃរាជានិយម មកទទួលគំនិតពី "មគ្គុទេសនៃរាស្ត្រសាមញ្ញ" វិញបានហើយ ៕






## តមកពីទំព័រទី ៦ ក្រុមអ្នកបកប្រែនៅសាលាក្តីខ្មែរក្រហមបន្ត...

បាលម្នាក់នាពេលរសៀលថ្ងៃដដែលនោះ ដោយប្រាប់បុគ្គលិកទាំងនោះថា ការធ្វើពហិការមិនចូលធ្វើការ គឺគ្មានមូលដ្ឋានច្បាស់លាស់ឡើយ ហើយចៅក្រមក៏ទទួលរងការព្រមានផងដែរ ។ ពួកគេក៏បានប្រាប់បុគ្គលិកផងដែរថា សាលាក្តីនឹងមិនបើកប្រាក់ខែឱ្យទេ ប្រសិនបើមិនព្រមត្រឡប់ទៅធ្វើការវិញ ព្រោះផ្នែកអង្គការសហប្រជាជាតិកំពុងស្វែងរកជំនួយឱ្យពួកគេ ។

លោក ក្រាញ់ តូនី បានចុចផ្តាច់ការហៅទូរស័ព្ទរបស់អ្នកយកព័ត៌មានពីរដង កាលពីម្សិលមិញ ។

អ្នកបកប្រែរូបនេះ ក៏បានអំពាវនាវឱ្យរដ្ឋាភិបាល "ឈប់ជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់តុលាការ ហើយបានលើកឡើងថា ការជ្រៀតជ្រែកខាងនយោបាយ គឺជាមូលហេតុនាំឱ្យបុគ្គលិកជាតិទាំងនេះមិនទទួលបានប្រាក់ខែ ។

អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមបានលើកឡើងថា ការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយដ៏អូសបន្លាយជាយូរមក ហើយនេះបានធ្វើឱ្យម្ចាស់ជំនួយមានការព្រួយបារម្ភ ។

កាលពីម្សិលមានសេចក្តីរាយការណ៍មួយចំនួនបានលើកឡើងថា ការទទួលខុសត្រូវ គឺជាភារកិច្ចរបស់ប្រទេសម្ចាស់ជំនួយដែលត្រូវដោះស្រាយវិបត្តិប្រាក់ខែនេះ យោងតាមមាត្រា១៥នៃកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានចែងយ៉ាងច្បាស់ថា "ប្រាក់ខែ និងប្រាក់បំណាច់ផ្សេងៗរបស់ចៅក្រមកម្ពុជា និងបុគ្គលិកកម្ពុជាដ៏ទៃទៀត ជាបន្ទុករបស់រដ្ឋាភិបាលកម្ពុជា" ។

តាមគោលការណ៍រដ្ឋាភិបាល និងអង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវចំពោះប្រាក់ខែរបស់បុគ្គលិកជាតិ និងអន្តរជាតិ ។ តែតាមការអនុវត្តជាក់ស្តែងប្រាក់ខែសម្រាប់បុគ្គលិកជាតិ និងអន្តរជាតិ គឺមួយផ្នែកធំបានពីម្ចាស់ជំនួយ ។

ទោះជាយ៉ាងណាការសន្យារបស់រដ្ឋាភិបាលក្នុងការផ្តល់ថវិការចំនួន១.៨លានដុល្លារសម្រាប់ថវិការឆ្នាំ២០១៣ របស់សាលាក្តីខ្មែរក្រហមមិនគ្រប់គ្រាន់សម្រាប់បើកប្រាក់ខែឱ្យបុគ្គលិកទេ ហើយការខកខានមិនបានបើកប្រាក់ខែឱ្យបុគ្គលិកទាន់ពេលវេលានោះមានន័យថា រដ្ឋាភិបាលរំលោភលើកិច្ចព្រមព្រៀងរបស់ខ្លួន ។

ពេលទាក់ទងតាមទូរស័ព្ទកាលពីម្សិលមិញ លោក ឯក ថា អ្នកនាំពាក្យអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី មានប្រសាសន៍ថា រដ្ឋាភិបាលមិនមានថវិការបន្ថែមទៀតទេ ហើយលោកបានអំពាវនាវឱ្យប្រទេសម្ចាស់ជំនួយជួយផ្តល់ថវិការបន្ថែមទៀតមកឱ្យសាលាក្តីខ្មែរក្រហម ។

លោកបានមានប្រសាសន៍បន្ថែមថា "រដ្ឋាភិបាលមិនមានថវិការផ្តល់ឱ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៀតទេ ដោយសាររដ្ឋាភិបាលបានផ្តល់ឱ្យសាលាក្តីនេះ លើសថវិកាជាតិដែលខ្លួនបានលៃទុកសម្រាប់តុលាការកំពូលចំនួន២៥៧ភាគរយ និងលើសថវិកាសម្រាប់សាលាឧទ្ធរណ៍ចំនួន៣០០ភាគរយឯណោះ" ។

នៅពេលសួរថា តើហេតុដូម្តេចបានជារដ្ឋាភិបាលមានលទ្ធភាពជួលយន្តហោះឯកជនសម្រាប់មន្ត្រីរដ្ឋាភិបាលប្រើប្រាស់ ប៉ុន្តែមិនមានប្រាក់បើកប្រាក់ខែរបស់បុគ្គលិកខ្មែរនៅសាលាក្តីខ្មែរក្រហមនោះ លោក ឯក ថា បានបដិសេធមិនធ្វើអត្ថាធិប្បាយអ្វីចឹងដែរ ។

លោកមានប្រសាសន៍បន្តទៀតថា "នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាភាគីអន្តរជាតិ មិនអាចធ្វើការដោយគ្មានភាគីជាតិបានឡើយ ។ ពោលគឺប្រៀបដូចជាបក្សីមួយមិនអាចហើរបានដោយស្លាបតែម្ខាងបានឡើយ " ។

លោក ឯក ថា បានអំពាវនាវដល់ប្រទេសម្ចាស់ជំនួយឱ្យជួយផ្តល់ថវិកាបន្ថែមទៀតដល់សាលាក្តីខ្មែរក្រហម ។ យោងតាមគម្រោងថវិកាដែលបានកែប្រែរបស់ខ្លួនសម្រាប់ឆ្នាំនេះភាគីជាតិត្រូវការថវិកាចំនួន៩.៤លានដុល្លារសម្រាប់ប្រតិបត្តិការរបស់ខ្លួន ។

លោក នេត ភក្ត្រា អ្នកនាំពាក្យសាលាក្តីខ្មែរក្រហមមានប្រសាសន៍ថា លោកមិនបានដឹងអំពីគោលបំណងរបស់អង្គភាពអ្នកបកប្រែជាមុនទេ ហើយលោកមានការភ្ញាក់ផ្អើលនៅពេលពួកគេបានប្រកាសធ្វើកូដកម្មនេះ ។

លោក ភក្ត្រា បានលើកឡើងតាមអ៊ីម៉ែលថា "បុគ្គលិកខ្មែរដទៃទៀតដែលកំពុងប្រឈមនឹងបញ្ហាដូចសហការីរបស់ពួកគេនៅអង្គភាពបកប្រែដែរនោះ ក៏នឹងមិនចូលធ្វើការដែរ ប្រសិនបើពួកគេនៅតែមិនបានបើកប្រាក់ខែនោះ ពីព្រោះពួកគេមិនអាចរស់បានទេ ។ បុគ្គលិកទាំងអស់មានតួនាទីសំខាន់ ដើម្បីធ្វើឱ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានដំណើរការល្អទៅមុខ ។

កាលពីម្សិលមិញ គឺជាថ្ងៃដែលលោកហ្វីលីប សត (Phillip Short)ជាសាក្សីជំនាញ និងជាអ្នកនិពន្ធជីវប្រវត្តិរបស់ ប៉ុល ពត ត្រូវឡើងផ្តល់សក្ខីកម្ម ។

ដោយមិនសង្កេតឃើញពីការបញ្ចប់ការធ្វើកូដកម្មនេះ និង អៀង សារី ត្រូវបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតទៀតនោះ នៅមិនទាន់ដឹងច្បាស់ថា តើនៅពេលណាលោកសតនឹងផ្តល់សក្ខីកម្ម ឬក៏មិនផ្តល់នោះទេ ។

តទៅទំព័រទី ២០

APSARA WIRELESS COMPUTER

ទើបបើកថ្មី !

GRAND OPENING

285 Chelmsford St. Lowell, Ma 01851
Phone: (978)-455-0075
និយាយភាសាខ្មែរ: (978)-876-2875



▸ មានលក់ Sale
▸ ផ្តល់សេវា Service
▸ ជួសជុល Repair

ទូរស័ព្ទ WIRELESS •កុំព្យូទ័រ •ឡាបថប •បរិក្ខាទូរស័ព្ទ •បង់ថ្លៃប៊ីល [Bill Pays]

សូមទៅមើលកន្លែងផ្សេងទៀត Location II: Happy Computer Service
122 Merrimack Street. Lowell, MA 01852 / ទូរស័ព្ទ: (978) 970-1769



# ការិយាល័យមេធាវី ដ៏រីង និង បូរូស្គី
# LAW OFFICE DOERING & BOROWSKY, LLC

**ទទួលការពារផលប្រយោជន៍លោកអ្នក ករណីទូទៅតាមផ្លូវច្បាប់ដូចជា :**

. ករណីបើរបរពាណិជ្ជកម្ម និងផ្ទេរប្រាក់ក្នុងមុខជំនួញ
. ករណីទិញលក់អចលនវត្ថុ ដូចជាផ្ទះសម្បែង ដីធ្លីជាដើម
. រើសអើងនៅកន្លែងធ្វើការ
. ករណីអន្តោប្រវេសន៍

**ធ្លាប់មានបទពិសោធន៏ខ្ពស់ _ផ្តល់សេវាជីនតាមវិជ្ជាជីវ:ហើយតម្លៃក៏សមរម្យទៀតផង _យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**



General practice law office handing matters in :
Corporations and business Transations
Real Estate
Work Place discriminations
Immigration
Experienced, professional service and reasonable rate Interpreter available

Office: (215) 667-8118 1650 Market st. Ste 3600 Philadelphia, PA 19103
Cell: (215) 840-1364; Email: dblawyers@gmail.com

# បុណ្យផ្កាប្រាក់សាមគ្គី

**គណៈកម្មាធិការរៀបចំបុណ្យចូលឆ្នាំខ្មែរ**រួមជាមួយពុទ្ធបរិស័ទដែលមានរាយនាមដូចខាងក្រោម បានមូលមតិគ្នាជាឯកច្ឆ័ន្ទផ្តួចផ្តើមធ្វើ**បុណ្យផ្កាប្រាក់សាមគ្គី**មួយ នៅ**ថ្ងៃសៅរ៍ ទី២៣ ខែមិនា ឆ្នាំ២០១៣** ដើម្បីប្រមូលបច្ច័យយកទៅរៀបចំពិធី**បុណ្យចូលឆ្នាំថ្មីប្រពៃណីយខ្មែរ**ជាសាធារណៈ នៅថ្ងៃសៅរ៍ ទី១៣ ខែមេសា ឆ្នាំ២០១៣ ខាងមុខនេះ ។

**គណៈកម្មាធិការរៀបចំបុណ្យចូលឆ្នាំខ្មែរ** មានបំណងចង់រក្សាទំនៀមទំលាប់ និងប្រពៃណីយជាតិខ្មែរ ជាពិសេសដើម្បីផ្សព្វផ្សាយនូវល្បែងប្រជាប្រិយខ្មែរដែលជាកេរមរតកដ៏ថ្លៃថ្លាទាំងនោះ ដល់កុលបុត្រ កុលធិតាខ្មែរជំនាន់ក្រោយនៅសហរដ្ឋអាមេរិកឱ្យបានស្គាល់និងចងចាំគ្រប់ៗគ្នា ។ អាស្រ័យហេតុនេះ ខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា សូមនិមន្តនិងអញ្ជើញព្រះតេជគុណគ្រប់ព្រះអង្គ លោកយាយ លោកតា លោក លោកស្រី យុវជន យុវតី និងជនរួមជាតិខ្មែរនៅសហរដ្ឋអាមេរិក ចូលរួមក្នុងពិធី**បុណ្យផ្កាប្រាក់សាមគ្គី**នេះ ឱ្យបានច្រើនកុះករ ជួយចាប់កុសលនិងអនុមោទនាទទួលយកនូវមគ្គផលទៅតាមកំលាំងសទ្ធាជ្រះថ្លារៀងៗខ្លួន ។

## កម្មវិធីបុណ្យ

**ថ្ងៃ១២ កើត ខែផល្គុន ឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ២៥៥៦ ត្រូវនឹង**

**ថ្ងៃសៅរ៍ ទី២៣ ខែមិនា ឆ្នាំ២០១៣** (Saturday, March 23, 2013)

- **ម៉ោង៩:០០នាទី** : ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ នមស្សការ សមាទានសីល
- **ម៉ោង១០:៣០នាទី**: វេរភត្តហា ដារបង្សុកូលឧទ្ទិសកុសល.ប្រគេនចង្ហាន់ព្រះសង្ឃ
- **ម៉ោង១២:០០នាទី**: ទទួលទានអាហារជាកិច្ចបង្ហើយបុណ្យ

**ទីកន្លែង:** **វត្តពន្លឺពុទ្ធមគ្គ** (GLORY BUDDHIST TEMPLE)
**24 Cambridge Street, Lowell, MA 01851**

**ពត៌មានបន្ថែមសូមទាក់ទង: លោក វាសនា នួន** Tel: (978) 835 4996 **លោក សេងលី គង់** Tel: (978) 364 1911, **លោក ឱក គុណាយុត្តិ** Tel: (978) 996 6758 **លោក អ៊ូ សុវណ្ណ** Tel: (978) 735 4539

**សូមអរព្រះគុណ និងសូមអរគុណ ។**

# ANGKOR AUTO SERVICE,INC.
# ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៏២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស៊ូរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services

From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.



4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



Agent: Roeut Chak

# PK Property, Inc.
# ក្រុមហ៊ុនអចលនវត្ថុ លក់ ដូរ គ្រប់ប្រភេទ

ភីខេ ប្រភើធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**
- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២០០០sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២០០០/ខែ

5734 N.2nd Street, Philadelphia, PA 19120
២៥០០ sqft ពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១០០/ខែ

**កន្លែងភ្នាក់បៀរ** BEER DELI
- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត** Co. Laundry
- 100 Machines, 4500 sqft Asking $170,000
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ** Beer Distributor
- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡុងធ្វើក្រចក** Nail Salon
- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**
www.pkpropertyinc.com to check more listings and office information.




**តពីលេខមុន**



●●●នាងរអាក់រអួល ពោលដោយរន្ធត់ក្នុងអារម្មណ៍: "អត់ទេបងសំឡាញ់! បងកុំទៅណាបងជាចំណតតែមួយដ៏សែនសុខ,ជាកំពង់ដតែមួយគត់សម្រាប់ទូកនេះចងចតនៅ។ គ្មានបងទូកនេះមិនដឹងនឹងរសាត់អណ្តែតទៅទីណា ព្រោះក្តីស្នេហ៍ស្ថិតនៅក្នុងមហន្តរាយ !

ស្ថានភាពទុក្ខព្រួយនេះបានលេចឮដល់បងប្រុសខ្ញុំ...គាត់ក៏ធ្លាប់មានពេលណាមួយនោះសង្សាររបស់គាត់បានចាកចេញពីគាត់ទៅកសាងសំបុកស្នេហ៍ថ្មីជាមួយបុរសម្នាក់មានសម្បត្តិស្តុកស្តម្ភហើយបានទុកឱ្យគាត់រស់នៅកណ្តោចកណ្តែងក្នុងក្តីទុក្ខព្រួយអស់សង្ឃឹម ។ ភាពទុក្ខព្រួយរបស់យើងទាំងពីរបានសង្គ្រោះដោយបងប្រុសខ្ញុំ រួចហើយគាត់ក៏ជាប់បំណុលគេយ៉ាងធន់ដោយគាត់ខំប្រឹងទិញឱ្យទាល់តែបាននូវសុភមង្គលឱ្យប្អូនប្រុសជាទីស្រឡាញ់របស់គាត់ ។ ដូច្នោះហើយទើបការចូលស្តីដណ្តឹងនឹងភ្ជាប់ពាក្យរបស់យើងទាំងពីរបានប្រព្រឹត្តទៅជាបន្ទាន់ ។ ឯពេលមង្គលសម្រាប់អពាពិពាហ៍ក៏បានសម្រេចយកថ្ងៃទី២៨ មិនាឆ្នាំ១៩៧០គឺ១០ថ្ងៃក្រោយដែលសម្តេចស៊ីហនុត្រូវទម្លាក់ចេញពីឋានៈជាព្រះប្រមុខនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រទេសកម្ពុជាត្រូវស្រោចស្រប់សន្ធប់ដោយបាតុកម្មនា១រាលដាលទូទាំងផ្ទៃប្រទេសបង្កើតឡើងដោយប្រជារាស្ត្រដែលត្រូវការនូវព្រះអង្គម្ចាស់របស់គេ ។ សភាពវឹកវរអូសបន្លាយពីមួយថ្ងៃទៅមួយថ្ងៃបញ្ជាយោធា, បំរាមគោចរបានត្រូវរដ្ឋាភិបាលសារធារណរដ្ឋប្រកាសតត្រឹកតគ្រេងរឿងចរាចរត្រូវហាមឃាត់លើផ្ទៃប្រទេសទាំងមូល,អ្នកចេញដើរតាមផ្លូវនឹងត្រូវឆែកឆេរសាកសួរចំឡើយ ។ គ្មានរថយន្តឈ្នួល, គ្មានរថយន្តផ្សេង១,គ្មានទោចក្រយានយន្តចរាចរតាមផ្លូវថ្នល់,និយាយឱ្យខ្លីគឺមធ្យោបាយធ្វើដំណើរត្រូវហាមឃាត់ទាំងអស់។ **តទៅលេខក្រោយ**

# Amazing Moment

*By Phien Kim*

and my brother immersed in a debt to buy the happiness for his young and beloved brother. Therefore, our engagement have been done and finally the date of our marriage would be on March 28th 1970, 10 days after the overthrow of Prince Sihanouk, Premier Minister of the Cambodia Kingdom.

The Cambodia was overwhelming by endless manifestations all over the country by the people who claimed their need for the Prince. The chaotic events were lasting days after days, the Martial Laws of the Khmer Republic proclaimed the motion prohibited.

Any one out of home will be checked and investigated; no bus, no cars, no motorcycles, and no all means of transportation on the road. How can I go for my traditional wedding ceremony which will be held in the morning of March 28, at 122kms far away from home? Nobody dares accompany me to my wedding in this dangerous time even my verygood parents, my brothers and sisters. They said: "If you know to save your life you can marry her on further day, if you lose your life, nothing can happens." They were right but how can I listen to them? The image of my love one lonely standing to welcome the guesses is enough to tear my heart in pieces. No, I can't leave her alone in that mourn ceremony, I have to go if even I have to pay my life for her. She will be dishonored to be suspected as a girl cheated by her lover who is not coming to marry her. I run to my best friend with all my disappointment. He astonished, loudly asked: "Why are you still here, today is Marche 28 isn't it? Oh my friend! Why are you still here?" I replied him with my tear in my eyes: "How can I go, no means of transportation, I run everywhere to rent a motorcycle, no one dares to take the risk to accept my supplication." My friend said jokingly or seriously just God could know: "Why didn't you come to see me?" I looked at him seriously: "Can you rent me your motorcycle?" He smiled and asked me back: "Are you ready with your suitcase, your stuff?" I was happily answered: "Yes, I was ready since the day before yesterday, but I could not find any motorcycle for rent." He smiled and loudly said: "For you I do not need your rental payment, I could not leave you either to go alone. Now on board! He walked his motorcycle out and locked the door then looked at me: "Come on! What are you waiting for?" With amazing astonishment I asked him: "You could undergo so all the risk with me in this way?" He still smiled: "Why not my friend? That is the unique opportunity I could pay back what you have done for me."

Oh thank God! I could have such a friend like him. (Now he already died two year ago in Canada from stomach cancer.)

My friend kept the speed about 30kms/hour even he knew that I was late for ceremony. He said: "Don't worry to be late, but carefully look out for our safety." He was smoothly driving on the quiet road almost absent of human soul and murmured some incantation that I could not understand. Luckily we reached the ferry of Naek-Loeng, middle way to the destination with peaceful day of a dangerous travel. Then a ferry boat traversed *Continue next Issue*




ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe's Auto Service**

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកឺរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120: TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**

ខ្មែរជួសជុលរថយន្ត

**KHMER AUTO REPAIR**

**CAR INSPECTION, DIAGNOTIC & REPAIR**

**ត្រួតពិនិត្យរថយន្តបញ្ជរដ្ឋ**
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- ប៉ូមចរន្តទឹកវេឌីណាទ័រ
- សេវាត្រង់បីស្យុង
- មើលតម្រងទ្រនាប់ និងពីញ៉ុង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា សឺន សាន






**ដោយ : ម៉ម ឃីន**

ចាប់តាំងពីពេលនោះមក ភាគីខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យត្រូវមានអវត្តមានក្នុងការចូលរួមប្រជុំការងារចរចាគ្នាក្នុងន័យបង្រួបបង្រួមជាតិជាខ្មែរតែមួយនោះជារៀងរហូត ។

ចំណែកភាគីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលមានឯកឧត្តម សឺន សាន ជាប្រធានរណសិរ្សជាតិ និងលោកឧត្តមសេនីយ៍ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការកងកម្លាំងទ័ពកជរបខនៅតែមានវត្តមានចូលរួមចរចាពិភាក្សាគ្នាដដែល ។ កម្មវត្ថុនៃការប្រជុំពិភាក្សាគ្នានេះមានគោលបំណង និងគោលដៅ ដើម្បីរៀបចំការបោះឆ្នោតសកលទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សក្រោមការជួយជ្រោមជ្រែងរបស់អង្គការសហប្រជាជាតិដែលមានឈ្មោះជាអក្សរកាត់ថា អ៊ុនតាក់ (UNTAC) ។

ក្រោយពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែររណសិរ្សហ៊្វុនស៊ីនប៉ិច និងភាគីកម្ពុជាប្រជាមានិតលោក ហ៊ុន សែន បានរំលាយចោលនូវរណសិរ្សរបស់ខ្លួនហើយ ភាគីទាំងបីត្រូវបានប្តូរឈ្មោះទៅជាគណបក្សនយោបាយវិញ គឺមាន:

**១**-ភាគីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ចែកចេញទៅជា២គណបក្សនយោបាយ គឺ១-របស់លោកតាប្រធាន សឺន សាន ឈ្មោះគណបក្សប្រជាធិបតេយ្យនិយមព្រះពុទ្ធសាសនា និងទី២-របស់លោកឧត្តមសេនីយ៍ សក់ ស៊ុតសាខន ឈ្មោះគណបក្សប្រជាធិបតេយ្យសេរីនិយម ។

២-ភាគីហ៊្វុនស៊ីនប៉ិចរបស់ទ្រង់នរោត្តម រណឫទ្ធិ ឈ្មោះគណបក្សហ៊្វុនស៊ីនប៉ិច ។

**៣-ភាគីកម្ពុជាប្រជាមានិតរបស់លោក ហ៊ុន សែន ឈ្មោះគណបក្សប្រជាជនកម្ពុជា ។**

គណបក្សនិមួយៗមានរូបសញ្ញាប្រចាំគណបក្សដូចជាគណបក្សប្រជាធិបតេយ្យលោកតា សឺន សាន មានរូបសញ្ញាក្បាលដំរីមានប្រមោយកាន់ផ្កាឈូកពាលើកឡើងលើ ។

គណបក្សប្រជាធិបតេយ្យលោកឧត្តមសេនីយ៍ សក់ ស៊ុតសាខន មានរូបសញ្ញាដំរីពេញតួ ។

គណបក្សប្រជាជនកម្ពុជាមានរូបសញ្ញាទេវតាហោះបាច់ផ្កា បន្ទាប់ពីបានបង្កើតគណបក្សនយោបាយគណបក្សនីមួយៗបានបើកសមាជមហាសន្និបាតរបស់ខ្លួន ដើម្បីបង្ហាញពីការបង្កើតគណបក្សឡើង ការបង្កើតគោលការណ៍បន្ទាត់នយោបាយ ការប្រកាសទទួលស្គាល់ជាផ្លូវការនៃការតែងតាំងប្រធានគណបក្ស ឈ្មោះគណបក្ស និងគោលការណ៍នយោបាយរបស់គណបក្ស ។ ក្រោយពីអង្គសមាជមហាសន្និបាតដែលមានតំណាងប្រជាពលរដ្ឋមកចូលរួមពីគ្រប់ស្ថាប័នជាតិ និងពីគ្រប់ខេត្តនៃប្រទេសកម្ពុជាទាំងមូល ។

គណបក្សប្រជាធិបតេយ្យនិយមព្រះពុទ្ធសាសនាក្តី គណបក្សប្រជាធិបតេយ្យសេរីនិយមក្រោយពីបានបើកធ្វើសមាជមហាសន្និបាតហើយក៏បានចាប់ផ្តើមធ្វើការឃោសនារកសម្លេងឆ្នោតជាបណ្តើរៗ រហូតដល់ពេលវេលាត្រូវកំណត់ឱ្យធ្វើយុទ្ធនាការឃោសនាបោះឆ្នោតសកលរយៈពេល១ខែ មុនពេលបោះឆ្នោត ។

នៅក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាក្រោមការជួយផ្តល់មធ្យោបាយខ្លះពីអង្គការអ៊ុនតាក់ ក៏រិតទឹកចិត្តអ្នកពេញចិត្ត និងគាំទ្រខ្លាំងជាងគេ បានទៅលើគណបក្សហ៊្វុនស៊ិចប៉ិចដែលជាគណបក្សរាជានិយម មានព្រះរាជបុត្រសម្តេចនរោត្តម សីហនុ ជាប្រធានគណបក្សដែលព្រះអង្គជាអតីតព្រះមហាក្សត្រ ព្រះប្រមុខរដ្ឋ និងជាបច្ចុប្បន្នប្រធានគណកម្មាធិការឧត្តមក្រុមប្រឹក្សានៃប្រជាជនកម្ពុជាទៀតផង ។

ទោះបីគណបក្សប្រជាជនកម្ពុជាបានប្រើអំណាចរបស់ខ្លួន ដោយចាត់ទុកថា ជាម្ចាស់ដឹកនាំប្រទេសខ្មែរ តាំងពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩មក ព្រមទាំងប្រើអំណាចក្នុងការប្រើប្រាស់គ្រប់មធ្យោបាយឃោសនាធំៗ ដូចជាវិទ្យុទូរទស្សន៍ វិទ្យុផ្សាយសម្លេង សារព័ត៌មាន ដោយផ្តាច់មុខតែម្នាក់ឯងយ៉ាងណាក៏ដោយ ក៏គណបក្សប្រជាជនកម្ពុជាពុំទាន់មានសមិទ្ធផលអ្វីធំដុំមកអួតអាង ក្រៅពីកងទ័ពយួនក្រហមប្រមាណ២សែននាក់ ឱ្យលើកទ័ពមកវាយ ដេញកំចាត់បនក្រុមខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យឱ្យធ្លាក់ពីអំណាច ។ រួចហើយរំដោះសង្គ្រោះជនជាតិខ្មែរឱ្យបានរស់រានមានជីវិតសារជាថ្មី គឺជាជីវិតទី២រហូតមកដល់សព្វថ្ងៃតែប៉ុណ្ណោះ ។ ពីព្រោះការកសាងស្ថាបនាប្រទេស និងប្រជាជាតិគណបក្សនេះកំពុងស្ថិតនៅក្នុងសភាពមានបាតដៃទទេមានន័យថា **តទៅលេខក្រោយ**


## ក្រុមហ៊ុនធានារ៉ាប់រងដែលបានបំរើសង្គម២២ឆ្នាំហើយ

**CONWAY INSURANCE**



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

**www.ConwayInsurance.com**

សូមសួររក Philip Muth, Philip@ConwayInsurance.com

## East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products Tummy Tuck Breast Lift Beast Enlargement



Nose Surgery Eyelid Surgery Face Lift Dermabrasion

**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមានអាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

## តមកពីទំព័រទី ១៦ ក្រុមអ្នកបកប្រែនៅសាលាក្តីខ្មែរក្រហមបន្ត...

លោក ម៉ៃ ឃើញ កាណាវ៉ាស (Michael Karnavas) មេធាវីអន្តរជាតិរបស់ អៀង សារី បានប្រសាសន៍នៅក្រៅតុលាការកាលពីម្សិលមិញថា លោកបានដឹងនៅម៉ោង៧ និង១០នាទីព្រឹកថា កូនក្តីរបស់លោកត្រូវបានបញ្ជូនទៅបន្ទប់សង្គ្រោះបន្ទាន់ ។

លោក កាណាវ៉ាស បានថ្លែងថា "យើងដឹងថា គាត់រាករុះខ្លាំង និងក្អួតទៀតផង" ។ លោកបានបន្ថែមថា វាពិបាកនឹងនិយាយថា មនុស្សដូចជាលោក អៀង សារី បដិសេធមិនចូលរួមនោះ ។ លោកក៏បានមានប្រសាសន៍ផងដែរថា បើទោះជាកូដកម្មនេះ គួរឱ្យលោកស្តាយក៏ដោយក៏វាសមហេតុផលដែរ ។

លោកបានបន្ថែមថា "នៅពីក្រោយពួកគេមានគ្រួសារពឹងផ្អែកលើប្រាក់ខែនេះ" ។

លោក គី ប៊ូស័រ វេជ្ជបណ្ឌិតនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានមានប្រសាសន៍ថា អៀង សារី បានមកដល់នៅម៉ោង៧ និង៣០នាទីព្រឹក ។

លោកវេជ្ជបណ្ឌិតបានបន្ថែមថា គាត់ឈឺក្រពះ និងឆ្អល់ចុងដង្ហើម ។ យើងមិនដឹងថា គាត់សម្រាកក្នុងមន្ទីរពេទ្យរយៈពេលប៉ុន្មានទេ វាអាស្រ័យលើស្ថានភាពជំងឺរបស់គាត់" ។

បន្ទាប់ពីការសេចក្តីប្រកាសអំពីការធ្វើកូដកម្ម និងបញ្ឈប់សវនាការជំនុំជម្រះមនុស្សប្រមាណ ៥០០នាក់ ដែលមកពីខេត្តកំពង់ស្ពឺ និងខេត្តតាកែវ បានត្រឡប់ទៅផ្ទះវិញទាំងខកចិត្តខ្លាំង ។

លោក ថាប់ ប៊ុនធាង អាយុ៥៨ ឆ្នាំមកពីខេត្តបន្ទាយមានជ័យដោយសង្ឃឹមថា នឹងបានចូលរួមសវនាការនៅពេលរសៀវ បានបង្ហាញនូវការមិនសប្បាយចិត្តចំពោះការមិនបានឃើញនីតិវិធី ។

លោកបន្ថែមថា "ខ្ញុំចង់ឃើញនីតិវិធីរបស់តុលាការនេះ តើវាត្រឹមត្រូវ ឬអត់" ។

លោក ឡុង បញ្ញាវុធ មន្ត្រីកម្មវិធីប្រចាំអង្គការគំនិតផ្តួចផ្តើមយុត្តិធម៌កម្ពុជា បានមានប្រសាសន៍ថា កាន់តែច្បាស់ជាងនេះទៀតនោះគឺថា បញ្ហាមូលនិធិ និងសុខភាព គឺជាការប្រឈមពីរដ៏ធំបំផុតរបស់តុលាការនេះ ។

លោកបានបន្តថា "ការផ្តល់មូលនិធិ គឺជាបញ្ហាធំមួយ ហើយបញ្ហាសុខភាពនៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភដែលអាចរារាំងដល់នីតិវិធីរបស់សាលាក្តីនេះ ។ ខ្ញុំគិតថា វាសំខាន់ណាស់ក្នុងការបើកប្រាក់ខែឱ្យបុគ្គលិក..." ។

នេះជាការសាកល្បងថា តើរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចំពោះការគោរពច្បាប់ និងការបញ្ចប់និទណ្ឌភាព និងការផ្តល់ការគាំទ្រ ថែមទៀត ដើម្បីឱ្យពួកគេអាចចូលរួមធ្វើឱ្យនីតិវិធីដំណើរការទៅទៀត ឬយ៉ាងណា ៕

*(រាយការណ៍បន្ថែមដោយ ឃី សុវុឌ្ឍី និង ជិន ចន្ទ)*

*ប្រែសម្រួលដោយ សោម សារុន និង ឃិន វ៉ៃណា*

## តមកពីទំព័រទី ១៦ និយោជិតក្រុមហ៊ុនអឹមហ្វូនទាមទារប្រាក់ខែ...

ដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីទាមទារឱ្យក្រុមហ៊ុនអឹមហ្វូនសងបំណុលខ្លួន ។ ក្រុមហ៊ុនហួវ៉ី តិចណូឡូជី ឃូអិលធីឌី (Huawei Technologies Co.,Ltd) ដែលជាទូរគមនាគមន៍ចិនដ៏ធំមួយបានដាក់ពាក្យបណ្តឹងដោយចោទប្រកាន់ថា ក្រុមហ៊ុនអឹមហ្វូននៅជំពាក់បំណុលខ្លួនចំនួន៦៥លានដុល្លារ ហើយក្រុមហ៊ុនអែល ធែក (Eltek) របស់ប្រទេសន័រវែសបានអះអាងថា ក្រុមហ៊ុនអឹមហ្វូននៅជំពាក់បំណុលខ្លួន៣,៧៣ លានដុល្លារ ។

សាលាដំបូងរាជធានីភ្នំពេញបានចេញអធិបញ្ញាចំនួនពីរ មួយចេញកាលពីថ្ងៃទី១៨ ខែតុលា ហើយមួយទៀតចេញកាលពីថ្ងៃទី១៧ ខែមករា ដើម្បីរារាំងក្រុមហ៊ុនអឹមហ្វូនកុំឱ្យលក់ទ្រព្យសម្បត្តិរបស់ខ្លួន ។ ក៏ប៉ុន្តែកាលពីខែមករា ក្រុមហ៊ុនអឹមហ្វូនបានផ្ទេរអតិថិជនរបស់ខ្លួនប្រហែល ៤០០.០០០នាក់ ទៅឱ្យក្រុមហ៊ុនម៉ូប៊ីថែល (MobiTel) ហើយក្រុមហ៊ុនទាំងអស់ដែលបានដាក់ពាក្យប្តឹងក្រុមហ៊ុនអឹមហ្វូនបានលើកឡើងថា ការផ្ទេរអតិថិជននេះជាការរំលោភលើអធិបញ្ញារបស់តុលាការ ។

ក្រុមបុគ្គលិក និងអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអឹមហ្វូនបានជួបជាមួយក្រុមមន្ត្រីក្រសួងការងារកាលពីម្សិលមិញ ដើម្បីព្យាយាមស្វែងរកដំណោះស្រាយមួយជុំវិញបញ្ហាប្រាក់ខែ ។

លោក វង់ សាវណ្ណ អគ្គលេខាធិការរងគណៈកម្មការដោះស្រាយវិវាទការងារនៅក្រសួងការងារ បានមានប្រសាសន៍ថា កាលពីដំបូងបុគ្គលិកក្រុមហ៊ុនអឹមហ្វូន ទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ខែចំនួន៧៥ភាគរយនៃប្រាក់ខែរបស់ពួកគាត់ចាប់ពីពេលការងារនៅក្រុមហ៊ុនត្រូវបានឈប់ធ្វើការពីខែមករា ។ ក៏ប៉ុន្តែកាលពីម្សិលមិញ ពួកគាត់យល់ព្រមបញ្ចុះការទាមទាររបស់ខ្លួនមកនៅត្រឹម៥០ភាគរយវិញ ៕

*ប្រែសម្រួលដោយ ហួង កុកទៀនរ*


**ហ្វ្រេជិនខ្មែរវីដេអូ**

មានជួលនិងលក់កុនចិន-ថៃ-ខ្មែរ-ឥណ្ឌាគ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ ខារ៉ាអូខេថ្មីៗ

742 Pottess Avenue

Providence, RI 02907 ទូរស័ព្ទ : (401) 787 6663


# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហោង

ជោគជតាប្រចាំសប្តាហ៍

**ឆ្នាំជូត**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

**ឆ្នាំឆ្លូវ**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំខាល**

រាល់ការស្មគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអវហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

**ឆ្នាំថោះ**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

**ឆ្នាំរោង**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

**ឆ្នាំម្សាញ់**

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានគាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

**ឆ្នាំមមី**

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

**ឆ្នាំមមែ**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំវក**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើ អាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំរកា**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំច**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងឃាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

**ឆ្នាំកុរ**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕



# មានមធ្យោបាយប្រសើរមួយ ។

អ្នកមិនគួរចាំបាច់ប្រឹងហួសហេតុពេកដើម្បីមានសុខភាពល្អទេ ។

នោះគឺជាមូលហេតុដែលផែនការ CHIP និង Medicaid របស់យើងផ្តល់ជូន:

- សមាជិកភាព Y និង Fitness Center
- Weight Watchers®

*តម្លៃរហូតដល់ត្រឹមតែ $1,100 ក្នុងមួយឆ្នាំ!*

HEALTH PARTNERS
1-800-553-0784
www.healthpart.com

chip
Pennsylvania's Children's Health Insurance Program
យើងគិតដល់ក្មេងៗទាំងអស់ ។
www.chipcoverspakids.com

Kidz PARTNERS
គំរោងសំរាប់ក្មេងៗរបស់ HEALTH PARTNERS
1-888-888-1211
www.kidzpartners.com

# ផ្សារអាតាឡង់ទិក

## Atlantic Market

135 main St, Danbury, CT 06810

**203-830-3068**




ផ្សារនេះមានម្ចាស់ឈ្មោះ **ជាន់ ស៊ីម** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។

**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa

**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០




**ទីធ្លាចតរថយន្តឥតគិតថ្លៃ**



កំណាព្យ

# យប់យន់រងាគាលសព្វពុក

១-យប់យន់រងា សែនស្ងាត់ក្រៃ ព្រាត់ពីម្ចាស់ថ្លៃ ចាកឋានទៅ
ចោលកូនកំព្រា សែនម៉ង់សៅ យំស្រែកបួលហៅ ម្ចាស់ឪពុក ។
២-យប់យន់រងារ នៅឋានណា កូនចៅខ្លោចផ្សា ទឹកពេកក្រៃ
ទឹកសពកិរិយា ទឹកសំដី ស្នេហ៍កូនប្រុសស្រី ទាំងប្រពន្ធ ។
៣-យប់យន់រងា គ្មានសត្វយំ កូនទុក្ខដូចភ្នំ ធ្ងន់ពេកក្រៃ
ឃ្លាតពីឪពុក ដ៏ប្រពៃ កូនចៅប្រុសស្រី សែនសោកស្តាយ ។
៤-យប់យន់រងា សែនងងឹត ព្រាត់នេះព្រាត់ពិត លែងជួបហើយ
ពុកចាកឋានទៅ កូនចៅគ្មានស្បើយ គ្មានថ្ងៃទៀតឡើយ នឹងជួបភ័ក្ត្រ ។
៥-យប់យន់រងា ធ្លាក់ខ្យល់តិច ទឹកភ្នែកពព្រិច ហូរគ្មានស្បើយ
ហូរជោគថ្ពាល់ខ្ញុំ ព្រមទាំងខ្នើយ ឱលោកឪពុកអើយ សែនទឹកណា ។
៦-យប់យន់រងា មេឃគ្មានផ្កាយ ចិត្តសែនទ្បើយណាយ ទ្រូងសង្វេគ
ទោះកូនខំស្ងប់ ប្រឹងចូលដេក តែនឹកពុកពេក បែរជាយំ ។
៧-យប់យន់រងា ទឹកបានកក កូនដូចដង្ហក់ ក្នុងឱរ៉ា
គេងគាលសពពុក ម្ចាស់ជីវ៉ា កូនយំហៅប៉ា លោកស្ងៀមឈឹង ។
៨-យប់យន់រងា ភ្ញៀវទៅអស់ ទឹកមុខលែងស្រស់ ក្រៀមស្រពោន
ក្នុងវត្តសែនស្ងាត់ គាលសពស្ងួន រីឯបងប្អូន ក៏ទៅបាត់ ។
៩-យប់យន់រងា ឮសូរស្នូត សែនស្លូតរហូត ស៊្គកអង្គកាយ
កូនខំបែរបន់ ព្រះម្ចាស់ថ្លៃ លើកហត្ថបន់ថ្លៃ សូមបានស្ងប់ ។
១០-យប់យន់រងា ពេលជិតភ្លឺ សពពុកនឹងហែ ទៅបូជា
នឹងក្លាយជាផេះ ផ្ទូរផង់ណា កូននិងរក្សា ទុកក្នុងកោដិ ៕

**និពន្ធដោយលោក សូ ប៊ុនធឿន**
**ថ្ងៃសៅរ៍ទី២៩ ខែធ្នូ ឆ្នាំ២០១២**

Contiue From Page 09 **Bundith Ordered to Stand Trial for....**

this case caused a lot of damage, so the charge should be intentional murder," he said.

Local human rights groups Adhoc and the Cambodia Human Rights Action Committee (CHRAC), an umbrella organization of some 20 groups, criticized the judges for sending the case back to Svay Rieng province and the same court that dropped the charge against Mr. Bundith in December.

Mr. Bundith is also still employed as a government official in Svay Rieng province.

"We are concerned that the investigation will take place under the jurisdiction of Svay Rieng Provincial Court, which has proven once before that it may be susceptible to political pressure exerted by Mr. Bundith and his supporters," CHRAC and Adhoc said in a joint statement.

The statement also called on the provincial court "to ensure that the reinvestigation into the case against Mr. Bundith is conducted to the highest fair trial standards."

"A meaningful investigation into the shooting is necessary, not only to provide justice to the victims, but to assert the independence of the judiciary in Cambodia"

While human rights workers yesterday said they took the Appeal Court's decision to mean there would be a full reinvestigation into the case. Judge Leang Meng said that was not on the agenda.

"We sent this case to the Svay Rieng Provincial Court to go straight to trial; we did not send it for reinvestigation," he said, declining to explain why.

Svay Rieng Provincial Court director Pech Chhoeut also said there would be no reinvestigation of Mr. Bundith.

"According to the law, we do not have the right to reinvestigate this case," he said. "We will send it directly to trial."

During hearings at the Appeal Court last week, Mr. Bundith admitted to the court that he had fired a pistol into the air during the protest, but he claimed that he had no idea where his bullets went.

More than 20 police officers who were on duty during the factory protest and the shooting of the three workers told the Appeal Court that they had heard gunshots, but did not see who had fired them.

However, one officer, Prasat commune deputy police chief Long Phorn, testified last week to seeing Mr. Bundith level his pistol at the demonstrating factory workers and fire into the crowd, hitting at least one person.

On Friday, Mr. Phorn said one of his superiors subsequently called him to criticize his testimony and that he felt concerned for his safety and that of his family. On Sunday, the officer retracted his claim of intimidation, without explanation, though his wife expressed fear of reprisal because of her husband's court testimony.


• BEER
• WINE
• COFFEE

SOC TRANG
VIETNAMESE RESTAURANT

413
736-9999

113 VERMONT STREET. SPRINGFIELD, MA 01108




យើងមានសេចក្តីរីករាយ និងសូមអញ្ជើញលោកអ្នកព្រមទាំងគ្រួសារ អញ្ជើញមកពិសារម្ហូបពិសេស ចំអិនដោយចុងភៅដ៏ជំនាញរបស់យើង និងលំហែរកាយនៅសាលពិសារភោជនាហារ ដែលរៀបចំយ៉ាងប្រណិតសំរាប់ទទួលលោកអ្នក ។

ACCEPTING NEW PARTY BOOKINGS,
ASSOCIATION MEETINGS, BIRTHDAYS ETC
200 PEOPLE CAPACITY.



ម្ហូបពិសេស

- មានហ្វើ -មានគុយទាវ -មានបាយស្រូប មានគ្រឿងក្លែម
- មានបំរើភេសជ្ជៈស្រាបៀ និងភេសជ្ជៈមានសុរាតិច

ទទួលកក់ពិធីជប់លៀង ឬ
ធ្វើការប្រជុំរបស់សមាគម ឬ
ធ្វើបុណ្យខួបកំណើត...
(ឲ្យខ្ចីសាលមិនគិតថ្លៃ _យកតែថ្លៃបំរើម្ហូប)

Open Monday-Sunday
9 a.m. – 9 p.m.
Closed Thursdays

SPECIALS:
*PHO * NOODLES *RICE COMBO
*SERVE BEER, LIGHT ALCOHOL DRINKS.

"នាងប្រាប់ខ្ញុំគ្រប់យ៉ាង

# ខ្ញុំសប្បាយចិត្តខ្លាំងណាស់។

នាងពេញចិត្តនៅផ្ទះជាមួយយើង។"



CAREGIVER™ HOMES

Caregiver Homes™ ជួយចាស់ជរា និងជនពិការឱ្យរីករាយជាមួយ នឹងគុណភាពខ្ពស់នៃជីវិតនៅផ្ទះ

- បង់ប្រាក់ & បង្រៀបណ្តុះបណ្តាល អ្នកថែទាំពេញពេលដែលរស់នៅជាមួយ
- ផ្តល់ជំនួយ ប្រកបដោយវិជ្ជាជីវៈ ពីគិលានុបដ្ឋាយិកា និង អ្នកថែទាំ ដែលចេះយកចិត្តទុកដាក់
- ជួយអ្នកស្វែងរក & ទទួលបានគ្រប់សេវាដែលចាំបាច់

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **866.797.2333** ឬចូលមកគេហ៍ទំព័ររបស់យើង។

**WWW.CAREGIVERHOMES.COM**

# មជ្ឈមណ្ឌលសុខភាពពេលថ្ងៃសម្រាប់ជនពេញវ័យ

# HOME AWAY FROM HOME ADULT DAY HEALTH CENTER

នៅពេលលោកអ្នក ឬមនុស្សសំណព្វចិត្តរបស់លោកអ្នកត្រូវការគេជួយនៅពេលថ្ងៃ មជ្ឈមណ្ឌលយើងមានសេវាកម្មអ្នកថែទាំមានវិជ្ជាជីវៈ អាចនិយាយភាសាអង់គ្លេស ខ្មែរ ចិន និងស្បាញ៉ុល ។





### យើងអាចផ្តល់ជូនសេវា ដូចតទៅ :

- ថែទាំ សំអាត ធ្វើការសង្គមកិច្ចជូន និងព្យាបាលរាងកាយ
- ដឹកជញ្ជូនទៅមកពីផ្ទះទៅមជ្ឈមណ្ឌល និងទៅជួបពេទ្យ
- នាំចេញទៅភោជនីយដ្ឋានខ្មែរ –ទៅទិញឥវ៉ាន់ផ្សេងៗ ឬទៅមើលកន្លែងវប្បធម៌នានា
- មានការស្តាប់ និងលេងភ្លេង មើលកុន កំសាន្តល្បែង ថ្នាក់សិក្សា និងការហាត់ប្រាណរាល់ថ្ងៃ
- បើកទ្វារពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ពីម៉ោង៧ព្រឹកដល់៤ល្ងាច ឬក៏ប្តូរម៉ោងក៏បានតាមតម្រូវការ

**យើងទទួល អ៊ិនស្វរិន ស្ទើរគ្រប់មុខ**

- Mass Health • Evercare • Navicare • Senior Whole Health • Elder Services of the Merrimack Valley

## Our Services and Programs

- Nursing, social work and physical therapy
- Transportations
- Breakfast, lunch and snacks
- Outings to Cambodian restaurants, shopping, and cultural events
- Entertainments, spiritual classes and exercise daily

សូមទាក់ទងទៅ ខារិន បន គ្គារីហ្គាន់ (Karen Bond Garrigan) 978-453 Home (978-453-4663) ដើម្បីនាំទៅមើលមជ្ឈមណ្ឌល

Conveniently located at 150 Industrial Avenue East in Lowell, right off the Lowell Connector

Open Monday-Friday 7-4 and Saturday 7:30-2:00 PM

www.homeawayfromhomeADHC.com



ខ្មែរផុស
KhmerPost USA
Pin Samkhon
Soben Pin
PRESS CLUB | LOWELL | MA
3RD ANNUAL MEDIA & COMMUNITY BUILDING GALA
CELEBRATING THE CAMBODIAN NEW YEAR
“រាត្រីក្លឹបសារព័ត៌មានឆ្នាំទី៣នៅឡូវែល
រដ្ឋម៉ាសាឈូសែតប្រារព្ធនាឱកាសចូលឆ្នាំថ្មីខ្មែរ”
*សូមសាធារណជនអញ្ជើញចូលរួមសម្តែងមតិក្នុងក្លឹបសារព័ត៌មាន (ម៉ោង៦ដល់៨:៣០)
និងរីករាយជាមួយការល្បែងភោជនីហារ និងរាំកំសាន្តជាមួយក្រុមតន្ត្រីសម័យ
“តន្ត្រីយ៍មាស” នាពេលបន្តបន្ទាប់ -កុំភ្លេចនាំក្រុមគ្រួសារ និងញាតិមិត្តមករួមកំសាន្ត!
*នៅមានកម្មវិធីប្លែកៗខ្លះទៀត សំរាប់កំដរបរិយាកាសអឹកធឹកនាឱកាសចូលឆ្នាំថ្មីដែរ
Pailin Restaurant
68 Branch Street. Lowell, MA 01851
Friday March 29th, 2013. 6:00 PM – Midnight.
Fine Asian Cuisines | Cash Bar | Live Performances | Much More
Formal Attire
RSVP: KhmerPostUSA@gmail.com
Tickets: $30 Advance purchase | $35 after March 25th
Soben Pin: (978) 942-1641 / (267) 253-3947
KhmerPost USA has moved its" headquarter to Lowell, Massachusetts since November 2012 to better serve you.
Our readership is 40,000 mainly in Lowell, Lynn, and Revere Massachusetts.
Found April 2008, Philadelphia, Pennsylvania with mission to provide local news to an economically and socially isolated Cambodian Community in the East Coast.
It prints in Khmer and English to bridge the language and cultural gaps within the Cambodian American families and their neighboring communities.
Prints biweekly, 10,000 copies per edition, FREE!
For electronic print Archives: www.khmerpost.us. Like Us on Facebook: www.facebook.com/KhmerPostUSA